២០២៣

គណិតវិទ្យា ថ្នាក់ទី ១២

លីមីត និង ភាពជាប់ អនុគមន៍

អ្នករៀបរៀង៖ ខែម ពុទ្ធី

គណៈកម្មការរៀបរៀង	លោកគ្រូ ខែម ពុទ្ធី
ត្រួតពិនិត្យខ្លឹមសារ	លោកគ្រូ ខែម ពុទ្ធី
រៀបចំខ្លឹមសារ	លោកគ្រូ ខែម ពុទ្ធី
រចនាគម្រប និងទំព័រ	លោកគ្រូ ខែម ពុទ្ធី
រូបភាព និងតារាង	លោកគ្រូ ខែម ពុទ្ធី
កែសម្រួលអក្ខរាវិរុទ្ធ	លោកគ្រូ ខែម ពុទ្ធី
គណៈកម្មការពិនិត្យចុងក្រោយ	លោកគ្រូ ខែម ពុទ្ធី

សៀវភៅនេះត្រូវបានរៀបចំឡើងសម្រាប់សិស្សានុសិស្សថ្នាក់ទី១២ ជាពិសេសសម្រាប់ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងប្រឡងប្រកួតប្រជែងសិស្សពូកែគណិតវិទ្យា។

ព័ត៌មានសៀវភៅ

កំណែសាកល្បង © ២០២៦

លីមីតនៃអនុគមន៍

រៀបរៀងដោយ លោកគ្រូ ខែម ពុទ្ធី

សម្រាប់បោះពុម្ពផ្សាយ៖ បណ្ណាគារអង្គរ

ISBN 120 000 000 000

អារម្ភកថា

គណិតវិទ្យា គឺជាវិទ្យាសាស្ត្រមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពត្រិះរិះពិចារណា និងការដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ក្នុងចំណោមមែកធាងជាច្រើននៃគណិតវិទ្យា ការសិក្សាអំពី «លីមីតនៃអនុគមន៍» គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់បំផុតមួយនៃគណិតវិទ្យាវិភាគ (Calculus) ដែលសិស្សានុសិស្សថ្នាក់ទី១២ ចាំបាច់ត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់។ លីមីតមិនត្រឹមតែជាស្ពានចម្លងសម្រាប់ការសិក្សាទៅលើដេរីវេ និងអាំងតេក្រាលប៉ុណ្ណោះទេ តែថែមទាំងជាគន្លឹះក្នុងការយល់ដឹងអំពីបម្រែបម្រួលបាតុភូតផ្សេងៗផងដែរ។

ដោយយល់ឃើញពីសារៈសំខាន់នេះ និងកត់សម្គាល់ឃើញពីការលំបាករបស់សិស្សានុសិស្សមួយចំនួនក្នុងការស្វែងយល់អំពីការគណនាលីមីតរាងមិនកំណត់ ខ្ញុំបាទបានខិតខំស្រាវជ្រាវ និងចងក្រងសៀវភៅ «**លីមីតនៃអនុគមន៍**» នេះឡើង។ សៀវភៅនេះត្រូវបានរៀបចំឡើងយ៉ាងសម្រិតសម្រាំង ដោយបែងចែកជា ៤ ផ្នែកធំៗរួមមាន៖ មេរៀនសង្ខេប វិធីសាស្ត្រក្នុងការគណនា លំហាត់មានដំណោះស្រាយ និងលំហាត់ប្រតិបត្តិសម្រាប់អនុវត្ត ដើម្បីសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្សានុសិស្សឱ្យកាន់តែមានភាពងាយស្រួល និងស៊ីជម្រៅ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងក្លាយជាឯកសារយោងដ៏មានតម្លៃសម្រាប់ការត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) និងជួយជំរុញទឹកចិត្តសិស្សានុសិស្សទាំងអស់ឱ្យកាន់តែមានភាពជឿជាក់លើសមត្ថភាពរបស់ខ្លួន។ ទោះបីជាខ្ញុំបាទបានខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏កំហុសឆ្គងដោយអចេតនាអាចនឹងកើតមាន អាស្រ័យហេតុនេះខ្ញុំបាទរង់ចាំទទួលនូវរាល់មតិរិះគន់ស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកអានដោយក្តីសោមនស្សរីករាយបំផុត។

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

លោកគ្រូ ខែម ពុទ្ធី

សេចក្តីដឹងគុណ

ជាបឋម ខ្ញុំបាទ **លោកគ្រូ ខែម ពុទ្ធី** សូមលំអោនកាយវាចាចិត្ត ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះលោកអ្នកមានគុណទាំងពីរ គឺមាតា និងបិតារបស់ខ្ញុំ ដែលលោកទាំងពីរបានពលិកម្មគ្រប់បែបយ៉ាង ចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ និងអប់រំទូន្មានប្រៀនប្រដៅខ្ញុំបាទតាំងពីកល្យាណវ័យ រហូតធ្វើឱ្យរូបខ្ញុំអាចឈរយ៉ាងរឹងមាំនៅលើវិថីជីវិតមួយនេះ។ បើគ្មានការលះបង់ និងសេចក្តីស្រឡាញ់ដ៏មហាសាលពីលោកទាំងពីរទេ នោះខ្ញុំបាទក៏ប្រហែលជាគ្មានថ្ងៃនេះឡើយ។

ជាបន្តបន្ទាប់ ខ្ញុំបាទសូមសម្តែងនូវសេចក្តីគោរពដឹងគុណយ៉ាងស្មោះស្ម័គ្រ ជូនចំពោះលោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យគ្រប់លំដាប់ថ្នាក់ តាំងពីកម្រិតបឋមសិក្សា រហូតដល់ថ្នាក់សាកលវិទ្យាល័យ ដែលបានខិតខំចំណាយកម្លាំងកាយចិត្ត ក្នុងការផ្ទេរចំណេះដឹង និងបង្ហាត់បង្រៀនរូបខ្ញុំឱ្យក្លាយជាធនធានមនុស្សមួយរូបប្រកបដោយសមត្ថភាព។ រាល់ដំបូន្មានដែលទទួលបានពីលោកគ្រូ អ្នកគ្រូ គឺជាប្រទីបបំភ្លឺផ្លូវដែលតែងតែចង្អុលបង្ហាញឱ្យខ្ញុំបាទដើរលើគន្លងត្រឹមត្រូវ។

សៀវភៅ «**លីមីតនៃអនុគមន៍**» មួយក្បាលនេះ មិនអាចលេចចេញជារូបរាងឡើងបានឡើយ ប្រសិនបើគ្មានការលើកទឹកចិត្តពីមនុស្សជាច្រើនជុំវិញខ្លួនខ្ញុំ។ ខ្ញុំបាទសូមអរគុណដល់មិត្តភក្តិ បងប្អូន និងសហការីទាំងអស់ ដែលតែងតែផ្តល់មតិយោបល់ ជួយកែសម្រួល និងជួយជំរុញទឹកចិត្តខ្ញុំនៅក្នុងដំណើរការនៃការចងក្រងសៀវភៅនេះជាភាសា LaTeX ។ ជាចុងបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល ជូនដល់លោកអ្នកមានគុណ លោកគ្រូ អ្នកគ្រូ ព្រមទាំងមិត្តអ្នកសិក្សាទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ ប្រាជ្ញាភ្លឺថ្លា ជោគជ័យគ្រប់ភារកិច្ច និងសម្រេចបាននូវរាល់បំណងប្រាថ្នាក្នុងជីវិតជានិរន្តរ៍។

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៦

លោកគ្រូ ខែម ពុទ្ធី

មាតិកា



១ លីមីតនៃអនុគមន៍

១.១ សញ្ញាណលីមីត

បើ x ខិតជិត a ហើយអនុគមន៍ខិតជិតតម្លៃ L ណាមួយនោះគេកំណត់សរសេរ $\lim_{x\to a} f(x)=L$
មានន័យថា អនុគមន៍ $f(x)$ មានលីមីតស្មើ L កាលណា x ខិតជិត a ។

ឧទាហរណ៍ ១

អនុគមន៍ $f(x)=x+2$។ កាលណា x ខិតជិត 3 នោះ $f(x)$ ខិតជិតតម្លៃ $3+2=5$។ ដូចនេះគេសរសេរ $\lim_{x\to 3}(x+2)=5$។

លំហាត់គំរូ ១

ចូរទាញរកតម្លៃលីមីតនៃអនុគមន៍ $f(x)=\frac{x^2-1}{x-1}$ កាលណា x ខិតជិត 1។

ដំណោះស្រាយ

យើងដឹងថា $f(x)=\frac{(x-1)(x+1)}{x-1}=x+1$ ចំពោះ $x\neq 1$។
កាលណា $x\to 1$ នោះ $f(x)\to 1+1=2$។
ដូចនេះ $\lim_{x\to 1}\frac{x^2-1}{x-1}=2$។

១.២ និយមន័យទី១

បើអនុគមន៍ $f(x)$ មានលីមីត L កាលណា x ខិតជិត c បើគ្រប់ចំនួន $\varepsilon>0$ មានចំនួន$\alpha>0$
ដែល $0<|x-c|<\alpha$ នាំឱ្យ $|f(x)-L|<\varepsilon$ ។ គេកំណត់សរសេរដោយ: $\lim_{x\to c} f(x)=L$

ឧទាហរណ៍ ២

បង្ហាញថា $\lim\limits_{x\to 2} 4x = 8$ ។

ដំណោះស្រាយ

តាមនិយមន័យ គ្រប់ $\varepsilon > 0$ មាន $\alpha > 0$ ដែល $0 < |x-2| < \alpha$ នាំឱ្យ $|4x-8| < \varepsilon$។
គេមាន $|4x-8| < \varepsilon \Rightarrow 4|x-2| < \varepsilon \Rightarrow |x-2| < \frac{\varepsilon}{4}$។
ដូចនេះដោយយក $\alpha = \frac{\varepsilon}{4}$ នោះលក្ខខណ្ឌត្រូវបានផ្ទៀងផ្ទាត់។

លំហាត់គំរូ ២

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to 1}(3x+2) = 5$។

ដំណោះស្រាយ

ចំពោះគ្រប់ $\varepsilon > 0$ ត្រូវរក $\alpha > 0$ ដែល $0 < |x-1| < \alpha$ នាំឱ្យ $|(3x+2)-5| < \varepsilon$។
យើងមាន $|3x-3| < \varepsilon \Leftrightarrow 3|x-1| < \varepsilon \Leftrightarrow |x-1| < \frac{\varepsilon}{3}$។
ជ្រើសរើសយក $\alpha = \frac{\varepsilon}{3}$ នោះ $|x-1| < \alpha \Rightarrow |(3x+2)-5| < \varepsilon$ ។
ដូចនេះពិតជាបាន $\lim\limits_{x\to 1}(3x+2) = 5$។

១.៣ និយមន័យទី២

បើអនុគមន៍ f ខិតទៅជិត $+\infty$ កាលណា x ខិតទៅជិត a បើចំពោះចំនួន $M > 0$ មាន $\alpha > 0$ ដែល $0 < |x-a| < \alpha$ នាំឱ្យ $f(x) > M$ ។
គេកំណត់សរសេរដោយ $\lim\limits_{x\to a} f(x) = +\infty$

ឧទាហរណ៍ ៣

បង្ហាញថា $\lim\limits_{x\to 0} \frac{1}{x^2} = +\infty$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $M > 0$ ត្រូវរក $\alpha > 0$ ដែល $0 < |x-0| < \alpha$ នាំឱ្យ $\frac{1}{x^2} > M$។
គេមាន $\frac{1}{x^2} > M \Rightarrow x^2 < \frac{1}{M} \Rightarrow |x| < \frac{1}{\sqrt{M}}$។
ដោយយក $\alpha = \frac{1}{\sqrt{M}}$ នោះលក្ខខណ្ឌត្រូវបានផ្ទៀងផ្ទាត់។

លំហាត់គំរូ ៣

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to 2} \frac{1}{(x-2)^2} = +\infty$។

ដំណោះស្រាយ

ចំពោះគ្រប់ $M>0$ ត្រូវរក $\alpha>0$ ដែល $0<|x-2|<\alpha$ នាំឱ្យ $\frac{1}{(x-2)^2}>M$។
តម្រូវលក្ខខណ្ឌ $\frac{1}{(x-2)^2}>M \Leftrightarrow (x-2)^2<\frac{1}{M} \Leftrightarrow |x-2|<\frac{1}{\sqrt{M}}$។
ជ្រើសរើស $\alpha=\frac{1}{\sqrt{M}}$ នោះផ្ទៀងផ្ទាត់តាមនិយមន័យ។
ដូចនេះ $\lim\limits_{x\to 2}\frac{1}{(x-2)^2}=+\infty$។

១.៤ និយមន័យទី៣

បើអនុគមន៍ f ខិតទៅជិត $-\infty$ កាលណា x ខិតទៅជិត a បើចំពោះចំនួន $M>0$ មាន $\alpha>0$ ដែល $0<|x-a|<\alpha$ នាំឱ្យ $f(x)<-M$ ។ គេកំណត់សរសេរដោយ $\lim\limits_{x\to a}f(x)=-\infty$

ឧទាហរណ៍ ៤

បង្ហាញថា $\lim\limits_{x\to 0}\left(-\frac{1}{x^2}\right)=-\infty$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $M>0$ ត្រូវរក $\alpha>0$ ដែល $0<|x|<\alpha$ នាំឱ្យ $-\frac{1}{x^2}<-M$។
គេមាន $-\frac{1}{x^2}<-M \Rightarrow \frac{1}{x^2}>M \Rightarrow |x|<\frac{1}{\sqrt{M}}$។
យក $\alpha=\frac{1}{\sqrt{M}}$។

លំហាត់គំរូ ៤

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to 1}\frac{-2}{(x-1)^2}=-\infty$។

ដំណោះស្រាយ

ចំពោះគ្រប់ $M>0$ ត្រូវរក $\alpha>0$ ដែល $0<|x-1|<\alpha$ នាំឱ្យ $\frac{-2}{(x-1)^2}<-M$។
គេមាន $\frac{-2}{(x-1)^2}<-M \Leftrightarrow \frac{2}{(x-1)^2}>M \Leftrightarrow (x-1)^2<\frac{2}{M} \Leftrightarrow |x-1|<\sqrt{\frac{2}{M}}$។
ជ្រើសរើស $\alpha=\sqrt{\frac{2}{M}}$។
ដូចនេះ $\lim\limits_{x\to 1}\frac{-2}{(x-1)^2}=-\infty$។

១.៥ និយមន័យទី៤

បើអនុគមន៍ f ខិតជិត L កាលណា x ខិតជិត $+\infty$ បើចំពោះគ្រប់ចំនួន $\varepsilon>0$ មាន $N>0$ ដែល $x>N$ នាំឱ្យ $|f(x)-L|<\varepsilon$។ គេកំណត់សរសេរដោយៈ $\lim\limits_{x\to+\infty}f(x)=L$

ឧទាហរណ៍ ៥

បង្ហាញថា $\lim\limits_{x\to+\infty}\frac{1}{x}=0$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $\varepsilon>0$ ត្រូវរក $N>0$ ដែល $x>N$ នាំឱ្យ $\left|\frac{1}{x}-0\right|<\varepsilon$។
គេមាន $\frac{1}{|x|}<\varepsilon\Rightarrow|x|>\frac{1}{\varepsilon}$ ។ ដោយ $x\to+\infty$ យក $N=\frac{1}{\varepsilon}$។

លំហាត់គំរូ ៥

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to+\infty}\frac{2x+1}{x}=2$។

ដំណោះស្រាយ

ត្រូវរក $N>0$ ដែល $x>N$ នាំឱ្យ $\left|\frac{2x+1}{x}-2\right|<\varepsilon$ ចំពោះគ្រប់ $\varepsilon>0$។
គេមាន $\left|2+\frac{1}{x}-2\right|<\varepsilon\Leftrightarrow\left|\frac{1}{x}\right|<\varepsilon\Leftrightarrow x>\frac{1}{\varepsilon}$ (ដោយ $x>0$)។
យក $N=\frac{1}{\varepsilon}$ នោះវានឹងផ្ទៀងផ្ទាត់។
ដូចនេះ $\lim\limits_{x\to+\infty}\frac{2x+1}{x}=2$។

១.៦ និយមន័យទី៥

បើអនុគមន៍ f ខិតជិត L កាលណា x ខិតជិត $-\infty$ បើចំពោះគ្រប់ចំនួន $\varepsilon>0$ មាន $N>0$ ដែល $x<-N$ នាំឱ្យ $|f(x)-L|<\varepsilon$។ គេកំណត់សរសេរដោយ: $\lim\limits_{x\to-\infty}f(x)=L$

ឧទាហរណ៍ ៦

បង្ហាញថា $\lim\limits_{x\to-\infty}\frac{1}{x}=0$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $\varepsilon>0$ ត្រូវរក $N>0$ ដែល $x<-N$ នាំឱ្យ $\left|\frac{1}{x}\right|<\varepsilon$។
គេមាន $\frac{1}{|x|}<\varepsilon\Rightarrow|x|>\frac{1}{\varepsilon}$ ។ ដោយ $x<0$ នោះ $x<-\frac{1}{\varepsilon}$។
យក $N=\frac{1}{\varepsilon}$ នោះ $x<-N$។

លំហាត់គំរូ ៦

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to-\infty}\frac{x+5}{x}=1$។

ដំណោះស្រាយ

មេរៀនទី 1 មេរៀនសង្ខេប

ត្រូវរក $N>0$ ដែល $x<-N$ នាំឱ្យ $\left|\frac{x+5}{x}-1\right|<\varepsilon$។
គេមាន $\left|1+\frac{5}{x}-1\right|<\varepsilon \Leftrightarrow \frac{5}{|x|}<\varepsilon \Leftrightarrow |x|>\frac{5}{\varepsilon}$។
ដោយ $x<0$ នោះ $x<-\frac{5}{\varepsilon}$។
យក $N=\frac{5}{\varepsilon}$ ជាការស្រេច។
ដូចនេះ $\lim\limits_{x\to-\infty}\frac{x+5}{x}=1$។

១.៧ និយមន័យទី៦

បើអនុគមន៍ f ខិតជិត $+\infty$ កាលណា x ខិតជិត $+\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x>N$ នាំឱ្យ $f(x)>M$។ គេកំណត់សរសេរដោយ: $\lim\limits_{x\to+\infty}f(x)=+\infty$

ឧទាហរណ៍ ៧

បង្ហាញថា $\lim\limits_{x\to+\infty}x^2=+\infty$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $M>0$ ត្រូវរក $N>0$ ដែល $x>N$ នាំឱ្យ $x^2>M$។
គេមាន $x^2>M \Rightarrow x>\sqrt{M}$ (ព្រោះ $x\to+\infty$)។
យក $N=\sqrt{M}$។

លំហាត់គំរូ ៧

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to+\infty}(x+2)=+\infty$។

ដំណោះស្រាយ

ត្រូវរក $N>0$ ដែល $x>N$ នាំឱ្យ $x+2>M$ ចំពោះគ្រប់ $M>0$។
គេមាន $x+2>M \Leftrightarrow x>M-2$។
ប្រសិនបើ $M>2$ យក $N=M-2$។ បើ $M\leq 2$ យក $N=1$ ជាដើម។ ជាទូទៅយក $N=|M-2|+1$។
ដូចនេះ $\lim\limits_{x\to+\infty}(x+2)=+\infty$។

១.៨ និយមន័យទី៧

បើអនុគមន៍ f ខិតជិត $-\infty$ កាលណា x ខិតជិត $+\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x>N$ នាំឱ្យ $f(x)<-M$។ គេកំណត់សរសេរដោយ: $\lim\limits_{x\to+\infty}f(x)=-\infty$

ឧទាហរណ៍ ៨

បង្ហាញថា $\lim\limits_{x\to+\infty}(-x)=-\infty$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $M>0$ ត្រូវរក $N>0$ ដែល $x>N$ នាំឱ្យ $-x<-M$។
គេមាន $-x<-M\Rightarrow x>M$។
យក $N=M$។

លំហាត់គំរូ ៨

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to+\infty}(1-2x)=-\infty$។

ដំណោះស្រាយ

ត្រូវរក $N>0$ ដែល $x>N$ នាំឱ្យ $1-2x<-M$ ចំពោះគ្រប់ $M>0$។
គេមាន $1-2x<-M\Leftrightarrow -2x<-M-1\Leftrightarrow x>\frac{M+1}{2}$។
យក $N=\frac{M+1}{2}$។
ដូចនេះ $\lim\limits_{x\to+\infty}(1-2x)=-\infty$។

១.៩ និយមន័យទី៨

បើអនុគមន៍ f ខិតជិត $-\infty$ កាលណា x ខិតជិត $-\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x<-N$ នាំឱ្យ $f(x)<-M$។ គេកំណត់សរសេរដោយៈ $\lim\limits_{x\to-\infty}f(x)=-\infty$

ឧទាហរណ៍ ៩

បង្ហាញថា $\lim\limits_{x\to-\infty}x=-\infty$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $M>0$ ត្រូវរក $N>0$ ដែល $x<-N$ នាំឱ្យ $x<-M$។
នេះជារឿងងាយ ដោយគ្រាន់តែយក $N=M$ នោះនឹងបានការ។

លំហាត់គំរូ ៩

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to-\infty}(2x+3)=-\infty$។

ដំណោះស្រាយ

ត្រូវរក $N>0$ ដែល $x<-N$ នាំឱ្យ $2x+3<-M$ ចំពោះគ្រប់ $M>0$។
គេមាន $2x+3<-M\Leftrightarrow 2x<-M-3\Leftrightarrow x<\frac{-M-3}{2}=-\frac{M+3}{2}$។

យក $N=\frac{M+3}{2}$។
ដូចនេះ $\lim\limits_{x\to-\infty}(2x+3)=-\infty$។

១.១០ និយមន័យទី៩

បើអនុគមន៍ f ខិតជិត $+\infty$ កាលណា x ខិតជិត $-\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x<-N$ នាំឱ្យ $f(x)>M$។ គេកំណត់សរសេរដោយ: $\lim\limits_{x\to-\infty}f(x)=+\infty$

ឧទាហរណ៍ ១០

បង្ហាញថា $\lim\limits_{x\to-\infty}(-x)=+\infty$ ។

ដំណោះស្រាយ

ចំពោះគ្រប់ $M>0$ ត្រូវរក $N>0$ ដែល $x<-N$ នាំឱ្យ $-x>M$។
គេមាន $-x>M\Rightarrow x<-M$។
យក $N=M$។

លំហាត់គំរូ ១០

ដោយប្រើនិយមន័យបង្ហាញថា $\lim\limits_{x\to-\infty}x^2=+\infty$។

ដំណោះស្រាយ

ត្រូវរក $N>0$ ដែល $x<-N$ នាំឱ្យ $x^2>M$ ចំពោះគ្រប់ $M>0$។
គេមាន $x^2>M\Leftrightarrow|x|>\sqrt{M}$។
ដោយ $x\to-\infty$ (ពោលគឺ $x<0$) នោះ $-x>\sqrt{M}\Leftrightarrow x<-\sqrt{M}$។
យក $N=\sqrt{M}$។
ដូចនេះ $\lim\limits_{x\to-\infty}x^2=+\infty$។

១.១១ ប្រមាណវិធីលើលីមីត

បើ $\lim\limits_{x\to a}f(x)=L$ និង $\lim\limits_{x\to a}g(x)=M$ ដែល $(L,M,k,a\in\mathbb{R})$ នោះគេបានប្រមាណវិធីលើលីមីតដូចខាងក្រោម៖

១. $\lim\limits_{x\to a}k=k$

២. $\lim\limits_{x\to a}[kf(x)]=k\lim\limits_{x\to a}f(x)=k\times L$, k ជាចំនួនថេរ

៣. $\lim\limits_{x\to a}[f(x)+g(x)]=\lim\limits_{x\to a}f(x)+\lim\limits_{x\to a}g(x)=L+M$

៤. $\lim\limits_{x\to a}[f(x)-g(x)]=\lim\limits_{x\to a}f(x)-\lim\limits_{x\to a}g(x)=L-M$

៥. $\lim\limits_{x\to a}[f(x)g(x)]=\lim\limits_{x\to a}f(x)\times\lim\limits_{x\to a}g(x)=M\times L$

៦. $\lim\limits_{x\to a}\frac{f(x)}{g(x)}=\frac{\lim\limits_{x\to a}f(x)}{\lim\limits_{x\to a}g(x)}=\frac{L}{M}$, ដែល $M\neq 0$, $g(a)\neq 0$

៧. $\lim\limits_{x\to a}[f(x)]^n=[\lim\limits_{x\to a}f(x)]^n=L^n$, n ជាចំនួនគត់រ៉ឺឡាទីប វិជ្ជមាន

១.១២ ទ្រឹស្តីបទ

១. បើ $P(x)$ ជាពហុធា និង a ជាចំនួនពិត នោះគេបាន: $\lim\limits_{x\to a}P(x)=P(a)$

២. បើ $Q(x)$ ជាអនុគមន៍សនិទានដែល $Q(x)=\frac{p(x)}{r(x)}$ និង a ជាចំនួនពិតនោះគេបាន:
$\lim\limits_{x\to a}Q(x)=Q(a)=\frac{p(a)}{r(a)}$ ដែល $r(a)\neq 0$

៣. បើ $a>0$ និង $n\in\mathbb{N}$ ឬ $a\leq 0$ និង n សេស គេបាន: $\lim\limits_{x\to a}\sqrt[n]{x}=\sqrt[n]{a}=(a)^{\frac{1}{n}}$

៤. បើ $\lim\limits_{x\to a}f(x)=L$ និង $n\in\mathbb{N}$ ឬ $\lim\limits_{x\to a}f(x)\leq 0$ និង n សេស គេបាន:
$\lim\limits_{x\to a}\sqrt[n]{f(x)}=\sqrt[n]{\lim\limits_{x\to a}f(x)}=\sqrt[n]{L}=L^{\frac{1}{n}}$

៥. បើ f និង g ជាអនុគមន៍ដែល $\lim\limits_{x\to a}g(x)=L$ និង $\lim\limits_{x\to a}f(x)=L$ គេបាន:
$\lim\limits_{x\to a}f[g(x)]=f(L)$

៦. បើ a ជាចំនួនពិតនៅក្នុងដែនកំណត់នៃអនុគមន៍ត្រីកោណមាត្រគេបាន:

ក. $\lim\limits_{x\to a}\cos x=\cos a$ ខ. $\lim\limits_{x\to a}\sin x=\sin a$ គ. $\lim\limits_{x\to a}\tan x=\tan a$

ឃ. $\lim\limits_{x\to a}\cot x=\cot a$

១.១៣ លីមីតខាងឆ្វេង និង ខាងស្តាំ

១. បើអនុគមន៍ $f(x)$ ខិតជិត L កាលណា x ខិតជិតx_0 ពីខាងឆ្វេងនោះ L ជាលីមីតឆ្វេងនៃ $f(x)$ ហើយគេកំណត់សរសេរដោយ:
$\lim\limits_{x\to x_0^-}f(x)=L$ ។

២. បើអនុគមន៍ $f(x)$ ខិតជិត R កាលណា x ខិតជិតx_0 ពីខាងស្តាំនោះ R ជាលីមីតស្តាំនៃ $f(x)$ ហើយគេកំណត់សរសេរដោយ:
$\lim\limits_{x\to x_0^+}f(x)=R$ ។

៣. បើអនុគមន៍ $y=f(x)$ មានលីមីតត្រង់ x_0 លុះត្រាតែលីមីតឆ្វេង ស្មើនឹង លីមីតស្តាំ។

១.១៤ លីមីតអនន្តនៃអនុគមន៍អសនិទាន

! រូបមន្តសំខាន់ៗ

ក. $\lim\limits_{x\to a}\sqrt[n]{x}=\sqrt[n]{a}$

ខ. $\lim\limits_{x\to a}\sqrt[n]{f(x)}=\sqrt[n]{\lim\limits_{x\to a}f(x)}$

១.១៥ លីមីតអនន្តនៃអនុគមន៍

! រូបមន្តសំខាន់ៗ

ក. $\lim\limits_{x\to\pm\infty}ax^2=\begin{cases}+\infty & , \text{ បើ } a>0\\ -\infty & , \text{ បើ } a<0\end{cases}$

ខ. $\lim\limits_{x\to\pm\infty}\frac{a}{x}=0\ ,\ \forall a\in\mathbb{R}$

គ. $\lim\limits_{x\to\pm\infty}\frac{x}{a}=\infty\ ,\ a\neq 0$

១.១៦ លីមីតនៃអនុគមន៍ត្រីកោណមាត្រ

! រូបមន្តសំខាន់ៗ

ក. $\lim\limits_{x\to 0}\frac{\sin x}{x}=\lim\limits_{x\to 0}\frac{x}{\sin x}=1$

ខ. $\lim\limits_{x\to 0}\frac{\sin ax}{ax}=\lim\limits_{x\to 0}\frac{ax}{\sin ax}=1$

គ. $\lim\limits_{x\to 0}\frac{\sin^2 ax}{x^2}=a^2$

ឃ. $\lim\limits_{x\to 0}\frac{\tan x}{x}=\lim\limits_{x\to 0}\frac{x}{\tan x}=1$

ង. $\lim\limits_{x\to 0}\frac{\tan ax}{ax}=\lim\limits_{x\to 0}\frac{ax}{\tan ax}=1$

ច. $\lim\limits_{x\to 0}\frac{1-\cos ax}{x^2}=\frac{a^2}{2}$

ឆ. $\lim\limits_{x\to 0}\frac{1-\cos x}{x}=0$

ជ. $\lim\limits_{x\to 0}\frac{1-\cos ax}{ax}=0$

១.១៧ លីមីតនៃអនុគមន៍អិចស្ប៉ូណង់ស្យែល

! រូបមន្តសំខាន់ៗ

ក. $\lim\limits_{x\to 0}\frac{e^x-1}{x}=1$

ខ. $\lim\limits_{x\to+\infty}\frac{e^x}{x^n}=+\infty\ ,\ n>0$

គ. $\lim\limits_{x\to+\infty}\frac{x^n}{e^x}=0\ ,\ n\geq 0$

ឃ. $\lim\limits_{x\to 0}\frac{a^x-1}{x}=\ln a\quad ,\quad (a>0)$

ង. $\lim\limits_{x\to 0}(1+x)^{\frac{1}{x}}=\lim\limits_{x\to\infty}(1+\frac{1}{x})^x=e$

ច. $\lim\limits_{x\to+\infty}a^x=\begin{cases}+\infty & \text{ បើ } a>1\\ 0 & \text{ បើ } 0<a<1\end{cases}$

១.១៨ លីមីតនៃអនុគមន៍លោការីត

! រូបមន្តសំខាន់ៗ

ក. $\lim\limits_{x\to0}\frac{\ln(1+x)}{x}=1$

ខ. $\lim\limits_{x\to0^+}\ln x=-\infty$

គ. $\lim\limits_{x\to+\infty}\ln x=+\infty$

ឃ. $\lim\limits_{x\to+\infty}\frac{\ln x}{x}=0$

ង. $\lim\limits_{x\to1^+}\frac{\ln x}{x-1}=1$

ច. $\lim\limits_{x\to0^+}x\ln x=0$

ឆ. $\lim\limits_{x\to0^+}x^n\ln x=0$

ជ. $\lim\limits_{x\to+\infty}\frac{\ln x}{x^n}=0\ ,\ n>0$

ឈ. $\lim\limits_{x\to+\infty}n\ln x=+\infty\ ,\ n>0$

ញ. $\lim\limits_{x\to0}\frac{\log_a(x+1)}{x}=\log_a e$

ដ. $\lim\limits_{x\to0^+}\log_a x$

$\begin{cases}-\infty, a>0\\+\infty, 0<a<1\end{cases}$

$=$ ឋ. $\lim\limits_{x\to+\infty}x=\begin{cases}+\infty, a>1\\-\infty, 0<a<1\end{cases}$

⚠ សម្គាល់

បើគេមាន $\lim\limits_{x\to\infty}|x|$ គេបាន៖

- បើ x ខិតជិត $+\infty$ នោះគេបាន $|x|=+\infty$
- បើ x ខិតជិត $-\infty$ នោះគេបាន $|x|=-\infty$

២ ភាពជាប់នៃអនុគមន៍

២.១ ភាពជាប់ត្រង់មួយចំនុច

បើអនុគមន៍ $y=f(x)$ ជាប់ត្រង់ចំនុច $x=a$ លុះត្រាតែ

១. $f(a)$ មានន័យ , ($f(a)$ ជាចំនួនពិត)

២. $\lim\limits_{x\to a}f(x)=n$ ដែល $n\in\mathbb{R}$, (មានលីមីតជាចំនួនពិត)

៣. $\lim\limits_{x\to a}f(x)=f(a)$, (តម្លៃលីមីត ស្មើនឹង តម្លៃអនុគមន៍ត្រង់ $x=a$)

⚠ សម្គាល់

ក្នុងលក្ខខណ្ឌខាងលើ៖

- បើអនុគមន៍មិនបានបំពេញលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌទាំង៣ ខាងលើនោះវាមិនជាប់ត្រង់ $x=a$ ទេ បានន័យថាវាដាច់ត្រង់ $x=a$ ។
- បើអនុគមន៍ $f(x)$ ដាច់ត្រង់ $x=a$ នោះវាមិនកំណត់ត្រង់ $x=a$ ឬ លីមីតឆ្វេង មិនស្មើ លីមីតស្តាំ ក្នុងករណីនេះ

គេមិនអាចគូសរូបដោយមិនលើកដៃបានទេ ។

២.២ លក្ខណៈអនុគមន៍ជាប់

បើ a ជាចំនួនពិត ហើយ $f(x)$ និង $g(x)$ ជាប់ត្រង់ចំនុច $x=a$ នោះគេបាន:

១. $f(x)+g(x)$ ជាប់ត្រង់ $x=a$

២. $f(x)-g(x)$ ជាប់ត្រង់ $x=a$

៣. $f(x)\times g(x)$ ជាប់ត្រង់ $x=a$

៤. $\frac{f(x)}{g(x)}$ ជាប់ត្រង់ $x=a$ ដែល $g(x)\neq 0$

៥. $cf(x)$ ជាប់ត្រង់ $x=a$ ដែល c ជាចំនួនថេរ

៦. $\frac{1}{f(x)}$ ជាប់ត្រង់ $x=a$ ដែល $f(x)\neq 0$

៧. $[f(x)]^n$ ដែល n ជាចំនួនពិត ជាប់ត្រង់ $x=a$ កាលណាវាកំណត់ត្រង់ a នោះ ។

សម្គាល់

បើ
១.អនុគមន៍លីនេអ៊ែ ជាអនុគមន៍ជាប់ចំពោះគ្រប់ចំនួនពិត ។
២.អនុគមន៍ពហុធា $P(x)=a_nx^n+a_{n-1}x^{n-1}+\ldots+a_1x+a_0$ ជាអនុគមន៍ជាប់ចំពោះគ្រប់តម្លៃ x ។
៣. អនុគមន៍សនិទាន $r(x)=\frac{p(x)}{q(x)}$, $q(x)\neq 0$ ជាអនុគមន៍ជាប់ចំពោះគ្រប់តម្លៃ x ក្នុងដែនកំណត់ ។
៤.អនុគមន៍ឫសទី n, $f(x)=\sqrt[n]{x}$ ជាអនុគមន៍ជាប់ចំពោះគ្រប់តម្លៃ x ក្នុងដែនកំណត់
៥.អនុគមន៍ត្រីកោណមាត្រ $\sin x$, $\cos x$ ជាអនុគមន៍ជាប់ចំពោះគ្រប់តម្លៃ x ។
៦.អនុគមន៍ត្រីកោណមាត្រ $\tan x,\cot x$ ជាអនុគមន៍ជាប់ចំពោះគ្រប់តម្លៃ x ក្នុងដែនកំណត់។

២.៣ ភាពជាប់នៃអនុគមន៍បណ្តាក់

បើអនុគមន៍ g ជាប់ត្រង់ a ហើយអនុគមន៍ f ជាប់ត្រង់ $g(x)$ នោះគេបាន អនុគមន៍បណ្តាក់ $f\circ g(x)$ ជាប់ត្រង់ a ។

២.៤ ភាពជាប់លើចន្លោះមួយ

១. អនុគមន៍ $f(x)$ ជាប់លើចន្លោះបើក $]a,b[$ លុះត្រាតែ $f(x)$ ជាប់ចំពោះគ្រប់ $x\in]a,b[$

២. អនុគមន៍ $f(x)$ ជាប់លើចន្លោះបិទ $[a,b]$ លុះត្រាតែ:

ក. $f(x)$ ជាប់លើចន្លោះបើក $]a,b[$

ខ. $f(x)$ ជាប់ឆ្វេងត្រង់ b $\left[\lim_{x\to b^-} f(x)=f(b)\right]$

គ. $f(x)$ ជាប់ស្តាំត្រង់ a $\left[\lim_{x\to a^+} f(x)=f(a)\right]$

២.៥ ទ្រឹស្តីបទតម្លៃកណ្តាល

បើ $f(x)$ ជាប់លើចន្លោះ $[a,b]$ ហើយ $f(a).f(b)<0$ នោះយ៉ាងហោចណាស់ មានចំនួន c មួយនៅចន្លោះ a និង b ដែល $f(c)=0$ ។



មេរៀនទី ២
វិធីសាស្ត្រក្នុងការគណនា

១ ការគណនាលីមីតដោយប្រើនិយមន័យ

១.១ ករណីទី១

⚠ សម្គាល់

បើអនុគមន៍ $f(x)$ មានលីមីត L កាលណា x ខិតជិត c បើគ្រប់ចំនួនមានចំនួន$\alpha>0$ មាន $\varepsilon>0$ ដែល$0<|x-c|<\alpha$ នាំឱ្យ $|f(x)-L|<\varepsilon$ ។
គេកំណត់សរសេរដោយៈ $\lim\limits_{x\to c} f(x)=L$ ។

លំហាត់គំរូ ១

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to 2}(2001x-2000)=2002$

ខ. $\lim\limits_{x\to 2}(2x-1)=3$

គ. $\lim\limits_{x\to 4}(x^3-x^2-x)=-4$

ឃ. $\lim\limits_{x\to 3}\frac{x+1}{x-1}=2$

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to 2}(2001x-2000)=2002$
យើងត្រូវបង្ហាញថាគ្រប់ចំនួន $\varepsilon>0$ យើងបាន $|f(x)-L|<\varepsilon$
យើងមាន $|f(x)-L|<\varepsilon$

យើងបាន$|f(x)-L|<\varepsilon \Leftrightarrow |(2001x-2000)-2002|<\varepsilon$

$$\Leftrightarrow |2001x-4002|<\varepsilon$$
$$\Leftrightarrow |2001(x-2)|<\varepsilon$$
$$\Leftrightarrow |x-2|<\frac{\varepsilon}{2001}=\alpha \quad ;\text{យក}\ \alpha=\frac{\varepsilon}{2001}$$

ដោយ$\forall\ \varepsilon>0$, $\exists\ \alpha=\frac{\varepsilon}{2001}>0$ ដែល $|x-2|<\alpha$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to 2}(2001x-2000)=2002}$

ខ. $\lim\limits_{x\to 2}(2x-1)=3$

យើងត្រូវបង្ហាញថាគ្រប់ចំនួន $\varepsilon>0$ យើងបាន $|f(x)-L|<\varepsilon$

យើងមាន $|f(x)-L|<\varepsilon$

យើងបាន$|f(x)-L|<\varepsilon \Leftrightarrow |(2x-1)-3|<\varepsilon$

$$\Leftrightarrow |2x-4|<\varepsilon$$
$$\Leftrightarrow |2(x-2)|<\varepsilon$$
$$\Leftrightarrow |x-2|<\frac{\varepsilon}{2}=\alpha \quad ;\text{យក}\,\alpha=\frac{\varepsilon}{2}$$

ដោយ $\forall\varepsilon>0$ $\exists$ $\alpha=\frac{\varepsilon}{2}>0$, ដែល $|x-2|<\alpha$ នាំឱ្យ $|f(x)-L|<\alpha$

ដូចនេះ $\boxed{\lim\limits_{x\to 2}(2x-1)=3}$

គ. $\lim\limits_{x\to 4}(x^3-x^2-x)=-4$

យើងត្រូវបង្ហាញថាគ្រប់ចំនួន $\varepsilon>0$ យើងបាន $|f(x)-L|<\varepsilon$

យើងមាន $|f(x)-L|<\varepsilon$ យើងបាន

$$|f(x)-L|<\varepsilon \Leftrightarrow |(x^3-4x^2-x)+4|<\varepsilon$$
$$\Leftrightarrow |x^3-4x^2-x+4|<\varepsilon$$
$$\Leftrightarrow |x^2(x-4)-(x-4)|<\varepsilon$$
$$\Leftrightarrow |(x-4)(x^2-1)|<\varepsilon$$

តែ$x\to 4$យើងបាន$3<x<5 \Leftrightarrow 9<x^2<25$

$$\Leftrightarrow 9-1<x^2-1<25-1$$
$$\Leftrightarrow 8<x^2-1<24$$
$$\Leftrightarrow 8<|x^2-1|<24$$
$$\Leftrightarrow |x^2-1|<24$$
$$\Leftrightarrow |x-4||x^2-1|<|x-4|24$$

ដើម្បីបាន$|x-4||x^2-1|<\varepsilon$ យើងគ្រាន់តែយក

$|x-4|24<\varepsilon$ ឬ $|x-4|<\frac{\varepsilon}{24}=\alpha$;យក$\alpha=\frac{\varepsilon}{24}$

ដោយ $\forall\varepsilon>0$, $\exists$ $\alpha=\frac{\varepsilon}{24}>0$ ដែល $|x-4|<\varepsilon$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to 4}(x^3-x^2-x)=-4}$

ឃ. $\lim\limits_{x\to 3}\frac{x+1}{x-1}=2$

យើងត្រូវបង្ហាញថាគ្រប់ចំនួន $\varepsilon>0$ យើងបាន $|f(x)-L|<\varepsilon$

យើងមាន $|f(x)-L|<\varepsilon$

យើងបាន : $|f(x)-L|<\varepsilon \Leftrightarrow \left|\frac{x+1}{x-1}-2\right|<\varepsilon$

$$\Leftrightarrow \left|\frac{(x+1)-2(x-1)}{x-1}\right|<\varepsilon$$
$$\Leftrightarrow \left|\frac{x+1-2x+2}{x-1}\right|<\varepsilon$$
$$\Leftrightarrow \left|\frac{-x+3}{x-1}\right|<\varepsilon$$
$$\Leftrightarrow \frac{|x-3|}{|x-1|}$$
$$\Leftrightarrow |x-3|=\varepsilon|x-1|(*)$$

ដោយ$x\to 3$យើងបាន : $2<x<4 \Leftrightarrow 2-1<x-1<4-1$

$$\Leftrightarrow 1<x-1<3$$
$$\Leftrightarrow 1<|x-1|<3$$
$$\Leftrightarrow |x-1|<3$$
$$\Leftrightarrow \varepsilon|x-1|<3\varepsilon(**)$$

តាម $(*)$ និង $(**)$ យើងបាន $|x-3|<3\varepsilon$

ដោយ $\forall\,\varepsilon>0$, $\exists\,\alpha=3\varepsilon$, ដែល $|x-3|<\varepsilon$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to 3}\frac{x+1}{x-1}=2}$

១.២ ករណីទី២

សម្គាល់

បើអនុគមន៍f ខិតទៅជិត$+\infty$ កាលណាx ខិតទៅជិត a បើចំពោះចំនួន $M>0$
មាន$\alpha>0$ ដែល $0<|x-a|<\alpha$ នាំឱ្យ $f(x)>M$ ។
គេកំណត់សរសេរដោយ $\lim\limits_{x\to a}f(x)=+\infty$ ។

លំហាត់គំរូ ២

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to 1^+}\frac{7x+2}{x-1}=+\infty$ ខ. $\lim\limits_{x\to 1^-}\frac{x+8}{1-x}=+\infty$

មេរៀនទី ២ • វិធីសាស្ត្រក្នុងការគណនា

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to1^+}\frac{7x+2}{x-1}=+\infty$

តាមនិយមន័យ: $\forall M>0\ ,\ f(x)>M$

$$f(x)>M\Leftrightarrow\frac{7x+2}{x-1}>M$$
$$\Leftrightarrow 7+\frac{9}{x-1}>M$$
$$\Leftrightarrow\frac{9}{x-1}>M-7$$
$$\Leftrightarrow x-1<\frac{9}{M-7}$$

ដោយ $x\to1^+$ នោះយើងបាន $x-1>0$ នាំឱ្យ $0<x-1<\frac{9}{M-7}$, ដែល $\alpha=\frac{9}{M-7}>0$

យើងបាន $\forall M>0\ ,\ \exists\ \alpha=\frac{9}{M}$ ដែល$|x-1|<\alpha$នាំឱ្យ$|f(x)|>M$

ដូចនេះ $\boxed{\lim\limits_{x\to1^+}\frac{7x+2}{x-1}=+\infty}$

ខ. $\lim\limits_{x\to1^-}\frac{x+8}{1-x}=+\infty$

តាមនិយមន័យ: $\forall M>0\ ,\ f(x)>M$

$$f(x)>M\Leftrightarrow\frac{x+8}{1-x}>M$$
$$\Leftrightarrow -1+\frac{9}{1-x}>M$$
$$\Leftrightarrow\frac{9}{1-x}>M+1$$
$$\Leftrightarrow x-1<\frac{9}{M+1}$$

ដោយ $x\to1^-$ នោះយើងបាន $1-x>0$ នាំឱ្យ $0<1-x<\frac{9}{M+1}$, ដែល $\alpha=\frac{9}{M+1}>0$

យើងបាន $\forall M>0\ ,\ \exists\ \alpha=\frac{9}{M+1}$ ដែល$|x-1|<\alpha$នាំឱ្យ$|f(x)|>M$

ដូចនេះ $\boxed{\lim\limits_{x\to1^-}\frac{x+8}{1-x}=+\infty}$

១.៣ ករណីទី៣

សម្គាល់

បើអនុគមន៍f ខិតទៅជិត$-\infty$ កាលណាx ខិតទៅជិត a បើចំពោះចំនួន $M>0$ មាន$\alpha>0$ ដែល $0<|x-a|<\alpha$ នាំឱ្យ $f(x)<-M$ ។ គេកំណត់សរសេរដោយ $\lim\limits_{x\to a}f(x)=-\infty$ ។

លំហាត់គំរូ ៣

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to0^-}\frac{x+1}{x}=-\infty$

ខ. $\lim\limits_{x\to2^+}\frac{3x+3}{2-x}=-\infty$

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to0^-}\frac{x+1}{x}=-\infty$

តាមនិយមន័យ: $\forall M>0\ ,\ f(x)<-M$

$$f(x)<-M\Leftrightarrow\frac{x+1}{x}<-M$$
$$\Leftrightarrow 1+\frac{1}{x}<-M$$
$$\Leftrightarrow\frac{1}{x}<-M-1$$
$$\Leftrightarrow\frac{1}{|x|}<|-M-1|$$
$$\Leftrightarrow|x|<\frac{1}{M+1}$$

យក $\alpha = \frac{1}{M+1} > 0$
យើងបាន $\forall M > 0$,$\exists \alpha = \frac{1}{M+1}$ ដែល $|x| < \alpha$ នាំឱ្យ $|f(x)| < -M$
ដូចនេះ $\boxed{\lim\limits_{x\to 0^-} \frac{x+1}{x} = -\infty}$

ខ. $\lim\limits_{x\to 2^+} \frac{3x+3}{2-x} = -\infty$ តាមនិយមន័យ: $\forall M > 0$, $f(x) < -M$

$$f(x) < -M \Leftrightarrow \frac{3x+3}{2-x} < -M$$
$$\Leftrightarrow -3 - \frac{9}{x-2} < -M$$

ដើម្បីឲ្យ $f(x) < -M$, $\forall M > 0$; យើងគ្រាន់តែយក $-\frac{9}{x-2} < -M$
យើងបាន
$\left|-\frac{9}{x-2}\right| < |-M| \Leftrightarrow |x-2| < \frac{9}{M}$ យក $\alpha = \frac{9}{M}$
យើងបាន $\forall M > 0$ $\exists \alpha = \frac{9}{M}$ ដែល $|x-2| < \alpha$ នាំឱ្យ $f(x) < -M$
ដូចនេះ $\boxed{\lim\limits_{x\to 2^+} \frac{3x+3}{2-x} = -\infty}$

១.៤ ករណីទី៤

សម្គាល់

បើអនុគមន៍ f ខិតជិត L កាលណា x ខិតជិត $+\infty$ បើចំពោះគ្រប់ចំនួន $\varepsilon > 0$ មាន $N > 0$ ដែល $x > N$ នាំឱ្យ $|f(x) - L| < \varepsilon$។ គេកំណត់សរសេរដោយ: $\lim\limits_{x\to +\infty} f(x) = L$ ។

លំហាត់គំរូ ៤

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to +\infty} \frac{1}{x^2} = 0$

ខ. $\lim\limits_{x\to +\infty} \frac{2x+4}{x} = 2$

ដំណោះស្រាយ

ក. $\lim\limits_{x\to +\infty} \frac{1}{x^2} = 0$
តាមនិយមន័យ $\forall \varepsilon > 0$, $|f(x) - L| < \varepsilon$
យើងបាន $|f(x) - L| < \varepsilon \Leftrightarrow \left|\frac{1}{x^2} - 0\right| < \varepsilon$

$$\Leftrightarrow \left|\frac{1}{x^2}\right| < \varepsilon$$
$$\Leftrightarrow \frac{1}{|x^2|} < \varepsilon$$
$$\Leftrightarrow x^2 > \frac{1}{\varepsilon}$$
$$\Leftrightarrow |x| > \sqrt{\frac{1}{\varepsilon}}$$

ដោយ $x \to +\infty$ យើងបាន $|x| = x$ នាំឱ្យ $x > \sqrt{\frac{1}{\varepsilon}}$ យើងយក $N = \sqrt{\frac{1}{\varepsilon}} > 0$
យើងបាន $\forall \varepsilon > 0$, $\exists N = \sqrt{\frac{1}{\varepsilon}}$ ដែល $x > N$ នាំឱ្យ $|f(x) - L| < \varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to +\infty} \frac{1}{x^2} = 0}$

ខ. $\lim\limits_{x\to +\infty} \frac{2x+4}{x} = 2$
តាមនីយមន័យ $\forall \varepsilon > 0$, $|f(x) - L| < \varepsilon$
យើងបាន

$$|f(x) - L| < \varepsilon \Leftrightarrow \left|\frac{2x+4}{x} - 2\right| < \varepsilon$$
$$\Leftrightarrow \left|\frac{2x+4-2x}{x}\right| < \varepsilon$$
$$\Leftrightarrow \frac{4}{x} < \varepsilon$$
$$\Leftrightarrow |x| > \frac{4}{\varepsilon}$$

ដោយ $x \to +\infty$ យើងបាន $|x| = x$ នាំឱ្យ $x > \sqrt{\frac{4}{\varepsilon}}$ យើងយក $N = \sqrt{\frac{4}{\varepsilon}} > 0$
យើងបាន $\forall \varepsilon > 0$, $\exists N = \sqrt{\frac{4}{\varepsilon}}$ ដែល $x > N$ នាំឱ្យ $|f(x) - L| < \varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to +\infty} \frac{2x+4}{x} = 2}$

១.៥ ករណីទី៥

⚠ សម្គាល់

បើអនុគមន៍ f ខិតជិត L កាលណា x ខិតជិត $-\infty$ បើចំពោះគ្រប់ចំនួន $\varepsilon>0$ មាន $N>0$ ដែល $x<-N$ នាំឱ្យ $|f(x)-L|<\varepsilon$។ គេកំណត់សរសេរដោយៈ $\lim\limits_{x\to-\infty} f(x)=L$ ។

លំហាត់គំរូ ៥

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to-\infty}\frac{1}{x}=0$ ខ. $\lim\limits_{x\to-\infty}\frac{3x-1}{x-1}=3$

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to-\infty}\frac{1}{x}=0$

តាមនិយមន័យ $\forall\varepsilon>0$, $|f(x)-L|<\varepsilon$

យើងបាន$|f(x)-L|<\varepsilon=\left|\frac{1}{x}-0\right|<\varepsilon$

$$\Leftrightarrow \left|\frac{1}{x}\right|<\varepsilon$$

$$\Leftrightarrow \frac{1}{|x|}<\varepsilon$$

$$\Leftrightarrow |x|<\frac{1}{\varepsilon}$$

☒☒☒ $x\to-\infty$ យើងបាន $|x|=-x$ នាំឱ្យ $x<-\frac{1}{\varepsilon}$ យើងយក $N=\frac{1}{\varepsilon}>0$

យើងបាន$\forall\ \varepsilon>0, \exists=\frac{1}{\varepsilon}>0$ ដែល $x<-N$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to-\infty}\frac{1}{x}=0}$

ខ. $\lim\limits_{x\to-\infty}\frac{3x-1}{x-1}=3$

តាមនិយមន័យ $\forall\varepsilon>0$, $|f(x)-L|<\varepsilon$

យើងបាន

$$|f(x)-L|<\varepsilon \Leftrightarrow \left|\frac{3x-1}{x-1}-3\right|<\varepsilon$$

$$\Leftrightarrow \left|\frac{(3x-1)-3(x-1)}{x-1}\right|<\varepsilon$$

$$\Leftrightarrow \left|\frac{3x-1-3x+3}{x-1}\right|<\varepsilon$$

$$\Leftrightarrow \left|\frac{4}{x-1}\right|<\varepsilon$$

$$\Leftrightarrow |x-1|>\frac{2}{\varepsilon}$$

ដោយ $x\to-\infty$ យើងបាន $|x-1|=-(x-1)$ នាំឱ្យ $x-1<-\frac{2}{\varepsilon}$

យើងយក $N=\frac{2}{\varepsilon}>0$

យើងបាន$\forall\ \varepsilon>0$, $\exists N=\frac{2}{\varepsilon}>0$ ដែល $x>-N$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to-\infty}\frac{3x-1}{x-1}=3}$

១.៦ ករណីទី៦

⚠ សម្គាល់

បើអនុគមន៍ f ខិតជិត $+\infty$ កាលណា x ខិតជិត $+\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x>N$ នាំឱ្យ $f(x)>M$។

គេកំណត់សរសេរដោយៈ $\lim\limits_{x\to+\infty} f(x) = +\infty$ ។

លំហាត់គំរូ ៦

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to+\infty} \frac{x+2x^2}{3x+5} = +\infty$ ខ. $\lim\limits_{x\to+\infty} \frac{5x^2+4x-1}{x+2} = +\infty$

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to+\infty} \frac{x+2x^2}{3x+5} = +\infty$

តាមនិយមន័យ $\forall M>0$, $f(x)>0$

យើងបាន $f(x)>M \Leftrightarrow \dfrac{x+2x^2}{3x+5}>M$

$\Leftrightarrow \dfrac{x+2x^2}{3x+5}>M$

$\Leftrightarrow \dfrac{2}{3}x-\dfrac{7}{9}+\dfrac{\frac{35}{9}}{3x+5}>M$

ដោយ $x\to+\infty$ នោះយើងបាន $\frac{\frac{35}{9}}{3x+5}\to 0$

យើងបាន $\frac{2}{3}x-\frac{7}{9}+\frac{\frac{35}{9}}{3x+5}>M \Leftrightarrow \frac{2}{3}>M+\frac{7}{9}$

$\Rightarrow x>\frac{2}{3}\left(M+\frac{7}{9}\right)$ យើងយក $N=\frac{2}{3}\left(M+\frac{7}{9}\right)>0$

យើង បាន $\forall\ M>0$, $\exists N=\frac{2}{3}\left(M+\frac{7}{9}\right)$ ដែល $x>N$ នាំឱ្យ $f(x)>M$

ដូចនេះ $\boxed{\lim\limits_{x\to+\infty} \frac{x+2x^2}{3x+5} = +\infty}$

ខ. $\lim\limits_{x\to+\infty} \frac{5x^2+4x-1}{x+2} = +\infty$

តាមនិយមន័យ $\forall M>0$, $f(x)>0$

យើងបាន

$f(x)>M \Leftrightarrow \dfrac{5x^2+4x-1}{x+2}>M$

$\Leftrightarrow 5x-6+\dfrac{11}{x+2}>M$

ដោយ $x\to+\infty$ នោះយើងបាន $\frac{11}{x+2}\to 0$

យើងបាន $5x-6+\frac{11}{x+2}>M \Leftrightarrow 5x-6>M \Leftrightarrow 5x>M+6$

$\Rightarrow x>\frac{M+6}{5}$ យក $N=\frac{M+6}{5}>0$

យើងបាន $\forall M>0$, $\exists N=\frac{M+6}{5}$ ដែល $x>N$នាំឱ្យ $f(x)>0$

ដូចនេះ $\boxed{\lim\limits_{x\to+\infty} \frac{5x^2+4x-1}{x+2} = +\infty}$

១.៧ ករណីទី៧

⚠ សម្គាល់

បើអនុគមន៍ f ខិតជិត $-\infty$ កាលណា x ខិតជិត $+\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x>N$ នាំឱ្យ $f(x)<-M$។
គេកំណត់សរសេរដោយៈ $\lim\limits_{x\to+\infty} f(x) = -\infty$ ។

លំហាត់គំរូ ៧

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to+\infty} (-x^2) = -\infty$ ខ. $\lim\limits_{x\to+\infty} \frac{x^3-x+3}{1-x^2} = -\infty$

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim_{x\to+\infty}(-x^2)=-\infty$

តាមនិយមន័យ $\forall M>0$, $f(x)<-M$

$f(x)<-M \Leftrightarrow -x^2<-M$

$\Leftrightarrow x^2>M$

$\Leftrightarrow |x|>\sqrt{M}$

ដោយ $x\to+\infty$ នោះ $|x|=x \Rightarrow x>\sqrt{M}$ យើងយក $N=\sqrt{M}>0$

យើងបាន$\forall M>0$, $\exists N=\sqrt{M}$, ដែល $x>M$ នាំឱ្យ $f(x)<-M$

ដូចនេះ $\boxed{\lim_{x\to+\infty}(-x^2)=-\infty}$

ខ. $\lim_{x\to+\infty}\frac{x^3-x+3}{1-x^2}=-\infty$

តាមនិយមន័យ $\forall M>0$, $f(x)<-M$

$f(x)<-M \Leftrightarrow \dfrac{x^3-x+3}{1-x^2}<-M$

$\Leftrightarrow -x+\dfrac{3}{1-x^2}<-M$

ដោយ $x\to+\infty$ នោះយើងបាន $\frac{3}{1-x^2}\to 0$

យើងបាន $-x+\frac{3}{1-x^2}<-M \Leftrightarrow -x<-M$

$\Rightarrow x>M$ យក $N=M>0$

យើងបាន $\forall M>0$, $\exists N=M$ ដែល $x>N$ នាំឱ្យ $f(x)<-M$

ដូចនេះ $\boxed{\lim_{x\to+\infty}\frac{x^3-x+3}{1-x^2}=-\infty}$

១.៨ ករណីទី៨

សម្គាល់

បើអនុគមន៍ f ខិតជិត $-\infty$ កាលណា x ខិតជិត $-\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x<-N$ នាំឱ្យ $f(x)<-M$។ គេកំណត់សរសេរដោយ: $\lim_{x\to-\infty}f(x)=-\infty$ ។

លំហាត់គំរូ ៨

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim_{x\to-\infty}(1-x^2)=-\infty$

ខ. $\lim_{x\to-\infty}\frac{x^2+3}{x}=-\infty$

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim_{x\to-\infty}(1-x^2)=-\infty$

តាមនិយមន័យ $\forall M>0$, $f(x)<-M$

$f(x)<-M \Leftrightarrow 1-x^2<-M$

$\Leftrightarrow x^2>M+1$

$\Leftrightarrow |x|>\sqrt{M+1}$

ដោយ $x\to-\infty$ នោះ $|x|=-x$

យើងបាន $-x>\sqrt{M+1} \Leftrightarrow x<-\sqrt{M+1}$ យក $N=\sqrt{M+1}>0$

យើង បាន $\forall M>0$, $\exists N=\sqrt{M+1}$ ដែល $x<-N$ នាំ ឱ្យ $f(x)<-M$

ដូចនេះ $\boxed{\lim_{x\to-\infty}(1-x^2)=-\infty}$

ខ. $\lim_{x\to-\infty}\frac{x^2+3}{x}=-\infty$

តាមនិយមន័យ $\forall M>0$, $f(x)<-M$

$f(x)<-M \Leftrightarrow \dfrac{x^2+3}{x}<-M$

$\Leftrightarrow x+\dfrac{3}{x}<-M$

ដោយ $x\to-\infty \Leftrightarrow \frac{3}{x}\to 0$ យើងបាន $x<-M$ យក$N=M>0$

យើងបាន $\forall M>0$, $\exists N=M$ ដែល $x>N$ នាំឱ្យ $f(x)<-M$

ដូចនេះ $\boxed{\lim_{x\to-\infty}\frac{x^2+3}{x}=-\infty}$

១.៩ ករណីទី៩

សម្គាល់

បើអនុគមន៍ f ខិតជិត $+\infty$ កាលណា x ខិតជិត $-\infty$ បើចំពោះគ្រប់ចំនួន $M>0$ មាន $N>0$ ដែល $x<-N$ នាំឱ្យ $f(x)>M$ ។
គេកំណត់សរសេរដោយៈ $\lim\limits_{x\to-\infty} f(x)=+\infty$ ។

លំហាត់គំរូ ៩

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to-\infty}(x^2+2x+3)=+\infty$ ខ. $\lim\limits_{x\to-\infty}\frac{-x^2+6x}{2x+1}=+\infty$

ដំណោះស្រាយ

ដោយប្រើនិយមន័យបង្ហាញថា

ក. $\lim\limits_{x\to-\infty}(x^2+2x+3)=+\infty$

តាមនិយមន័យ $\forall M>0$, $f(x)>M$

$$f(x)>M \Leftrightarrow x^2+2x+3>M$$
$$\Leftrightarrow (x+1)^2+2>M$$
$$\Leftrightarrow (x+1)^2>M$$
$$\Leftrightarrow |x+1|>\sqrt{M}$$

ដោយ $x\to-\infty$ នោះ $|x+1|=-(x+1)$

យើងបាន $|x+1|>\sqrt{M}\Leftrightarrow x+1<-\sqrt{M}$

$\Rightarrow x<-(\sqrt{M}+1)$ យក $N=\sqrt{M}+1$

យើង បាន $\forall M>0$, $\exists N=(\sqrt{M}+1)$ ដែល $x<-N$ នាំឱ្យ $f(x)<-M$

ដូចនេះៈ $\boxed{\lim\limits_{x\to-\infty}(x^2+2x+3)=+\infty}$

ខ. $\lim\limits_{x\to-\infty}\frac{-x^2+6x}{2x+1}=+\infty$

$$f(x)>M\Leftrightarrow \frac{-x^2+6x}{2x+1}>M$$
$$\Leftrightarrow \frac{-x^2+6x}{2x+1}>M$$
$$\Leftrightarrow -\frac{1}{2}x+\frac{13}{4}-\frac{\frac{13}{4}}{2x+1}>M$$

ដោយ $x\to-\infty$ នោះយើងបាន $\frac{\frac{13}{4}}{2x+1}\to 0$

ដើម្បីបាន $f(x)>M$ យើងគ្រាន់តែយក $-\frac{1}{2}x>M\Rightarrow x<2M$ យក $N=2M>0$

យើងបាន $\forall M>0$, $\exists N=2M$, ដែល $x<-N$ នាំឱ្យ $f(x)>M$

ដូចនេះៈ $\boxed{\lim\limits_{x\to-\infty}\frac{-x^2+6x}{2x+1}=+\infty}$

២ របៀបគណនាលីមីត តាមការដាក់ជាផលគុណកត្តា

២.១ របៀប គណនា លីមីត តាម ការ ដាក់ជា ផលគុណ កត្តា រាងមិនកំណត់ $\frac{0}{0}$

សម្គាល់

• ប្រសិនបើលីមីតមានរាង $\lim_{x\to a}\frac{f(x)}{g(x)}$ ដែល $f(x)$ និង $g(x)$ ខិតជិត 0 នោះលីមីតរាងមិនកំណត់ $\frac{0}{0}$ ។ ក្នុងករណីនេះដើម្បីគណនា គេត្រូវបំបែកភាគយក និង ភាគបែងជាផលគុណកត្តាសិន បន្ទាប់មកសម្រួលកត្តាដែលដូចគ្នា រួចគណនាលីមីតថ្មីដែលនៅសល់។
• បើសិនជាសម្រួលហើយនៅតែរាងមិនកំណត់ $\frac{0}{0}$ ទៀតត្រូវដាក់ជាកត្តាដើម្បីសម្រួលបន្តទៀត រួចគណនាលីមីតថ្មីដែលនៅសល់។

រូបមន្តណែនាំសម្រាប់គណនាលំហាត់

សម្គាល់

ដើម្បីងាយស្រួលក្នុងការគណនាត្រូវចាំរូបមន្តមួយចំនួនដូចខាងក្រោម៖

1. $a^2-b^2=(a+b)(a-b)$
2. $a^3-b^3=(a-b)(a^2+ab+b^2)$
3. $a^3+b^3=(a+b)(a^2-ab+b^3)$
4. $a^4-b^4=(a^2-b^2)(a^2+b^2)=(a-b)(a+b)(a^2+b^2)$
5. $a^4+b^4=(a^2-ib^2)(a^2+ib^2)$
6. $a^5-b^5=(a-b)(a^4+a^3b+a^2b^2+ab^3+b^4)$
7. $a^5+b^5=(a+b)(a^4-a^3b+a^2b^2-ab^3+b^4)$

ក្នុងករណី n ជាចំនួនសេស

8. $a^n+b^n=(a+b)(a^{n-1}-a^{n-2}b+a^{n-3}b^2-...-ab^{n-2}+b^{n-1})$

ក្នុងករណី n ជាចំនួនគូ

9. $a^n-b^n=(a-b)(a^{n-1}+a^{n-2}b+a^{n-3}b^2+...+ab^{n-2}+b^{n-1})$
10. $a^n+b^n=(a+b)(a^{n-1}-a^{n-2}b+a^{n-3}b^2-...+ab^{n-2}-b^{n-1})$

លំហាត់គំរូ ១០

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to -1}\frac{x^5+1}{x^3+1}$ ខ. $\lim_{x\to 1}\frac{x^4-4x+3}{x^3-x^2-x+1}$ គ. $\lim_{x\to 2}\frac{x^6-x^2-60}{x^2-4}$

ឃ. $\lim_{x\to 3}\frac{x^2-5x+6}{x^2-9}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to -1}\frac{x^5+1}{x^3+1}$, រាងមិនកំណត់ $\frac{0}{0}$

តាមរូបមន្ត a^n+b^n យើងមាន

- $x^5+1=(x+1)(x^4-x^3+x^2-x+1)$
- $x^3+1=(x+1)(x^2-x+1)$

យើងបាន
$$\lim_{x\to -1}\frac{x^5+1}{x^3+1}=\lim_{x\to -1}\frac{\cancel{(x+1)}(x^4-x^3+x^2-x+1)}{\cancel{(x+1)}(x^2-x+1)}$$
$$=\lim_{x\to -1}\frac{x^4-x^3+x^2-x+1}{x^2-x+1}$$
$$=\frac{(-1)^4-(-1)^3+(-1)^2-(-1)+1}{(-1)^2-(-1)+1}$$
$$=\frac{5}{3}$$

ដូចនេះ $\boxed{\lim\limits_{x\to -1}\frac{x^5+1}{x^3+1}=\frac{5}{3}}$

ខ. $\lim\limits_{x\to 1}\frac{x^4-4x+3}{x^3-x^2-x+1}$, រាងមិនកំណត់ $\frac{0}{0}$

$$=\lim_{x\to 1}\frac{(x^4-x)-3(x-1)}{x^2(x-1)-(x-1)}$$
$$=\lim_{x\to 1}\frac{x(x-1)(x^2+x+1)-3(x-1)}{(x-1)(x^2-1)}$$
$$=\lim_{x\to 1}\frac{\cancel{(x-1)}[x(x^2+x+1)-3]}{\cancel{(x-1)}(x^2-1)}$$
$$=\lim_{x\to 1}\frac{x^3+x^2+x-3}{x^2-1}$$, (លីមីតថ្មីនៅតែរាងមិនកំណត់ $\frac{0}{0}$)
$$=\lim_{x\to 1}\frac{(x^3-1)+(x^2-1)+(x-1)}{(x-1)(x+1)}$$
$$=\lim_{x\to 1}\frac{\cancel{(x-1)}(x^2+x+1)+(x-1)(x+1)+(x-1)}{\cancel{(x-1)}(x+1)}$$
$$=\lim_{x\to 1}\frac{(x-1)[(x^2+x+1)+(x+1)+1]}{(x-1)(x+1)}$$
$$=\lim_{x\to 1}\frac{(x^2+x+1)+(x+1)+1]}{x+1}$$
$$=\lim_{x\to 1}\frac{(1^2+1+1)+(1+1)+1}{1+1}=3$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\frac{x^4-4x+3}{x^3-x^2-x+1}=3}$

គ. $\lim\limits_{x\to 2}\frac{x^6-x^2-60}{x^2-4}$, រាងមិនកំណត់ $\frac{0}{0}$

$$\lim_{x\to 2}\frac{\cancel{(x^2-4)}(x^4+4x^2+15)}{\cancel{x^2-4}}$$
$$\lim_{x\to 2}x^4+4x^2+15=16+16+15=47$$

ដូចនេះ $\boxed{\lim\limits_{x\to 2}\frac{x^6-x^2-60}{x^2-4}=47}$

ឃ. $\lim\limits_{x\to 3}\frac{x^2-5x+6}{x^2-9}$, រាងមិនកំណត់ $\frac{0}{0}$

យើងមាន

- $x^2-5x+6=(x-3)(x-2)$ និង $(x^2-9)=(x-3)(x+3)$

យើងបាន $\lim\limits_{x\to 3}\frac{x^2-5x+6}{x^2-9}=\lim\limits_{x\to 3}\frac{\cancel{(x-3)}(x-2)}{\cancel{(x-3)}(x+3)}$

$$=\lim_{x\to 3}\frac{x-2}{x+3}$$
$$=\frac{3-2}{3+3}=\frac{1}{6}$$

ដូចនេះ $\boxed{\lim\limits_{x\to 3}\frac{x^2-5x+6}{x^2-9}=\frac{1}{6}}$

៣ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន

៣.១ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន រាង $\sqrt{A}-B$

សម្គាល់

ប្រសិនបើកន្សោមមានរាង $\frac{\sqrt{A}-B}{F(x)}$ ឬ $\frac{G(x)}{\sqrt{A}-B}$ យើងត្រូវគុណនឹងកន្សោមឆ្លាស់គឺ $\sqrt{A}+B$ យើងបាន$(\sqrt{A}-B)(\sqrt{A}+B)=A-B^2$ ឬ $\sqrt{A}-B=\frac{A-B^2}{\sqrt{A}+B}$

លំហាត់គំរូ ១១

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 2}\frac{\sqrt{x^3+1}-3}{x^2-2x}$

ខ. $\lim\limits_{x\to 2}\frac{\sqrt{x^2-3}-1}{\sqrt{x+2}-2}$

គ. $\lim\limits_{x\to 1}\frac{x+1-\sqrt{x^2+3}}{\sqrt{x}-1}$

ឃ. $\lim\limits_{x\to 3}\frac{x^2-9}{x-1-\sqrt{x+1}}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 2}\frac{\sqrt{x^3+1}-3}{x^2-2x}$

យើងមាន៖

- $x^2-2x=x(x-2)$
- $\sqrt{x^3+1}-3=\sqrt{x^3+1}-3\times\frac{\sqrt{x^3+1}+3}{\sqrt{x^3+1}+3}$

$$=\frac{x^3+1-3^2}{\sqrt{x^3+1}+3}$$
$$=\frac{x^3-8}{\sqrt{x^3+1}+3}$$
$$=\frac{(x-2)(x^2+2x+4)}{\sqrt{x^3+1}+3}$$

យើងបាន $\lim\limits_{x\to 2}\frac{\sqrt{x^3+1}-3}{x^2-2x}=\lim\limits_{x\to 2}\frac{\cancel{(x-2)}(x^2+2x+4)}{x\cancel{(x-2)}(\sqrt{x^3+1}+3)}$

$$=\lim_{x\to 2}\frac{x^2+2x+4}{x(\sqrt{x^3+1}+3)}$$
$$=\frac{2^2+2\times 2+4}{2(\sqrt{2^3+1}+3)}$$
$$=1$$

ដូចនេះ៖ $\boxed{\lim\limits_{x\to 2}\frac{\sqrt{x^3+1}-3}{x^2-2x}=1}$

ខ. $\lim\limits_{x\to 2}\frac{\sqrt{x^2-3}-1}{\sqrt{x+2}-2}$, (គុណកន្សោមឆ្លាស់អង្គទាំងពីរ)

យើងបាន $\frac{\sqrt{x^2-3}-1}{\sqrt{x+2}-2}=\frac{\sqrt{x^2-3}-1}{\sqrt{x+2}-2}\times\frac{\sqrt{x^2-3}+1}{\sqrt{x^2-3}+1}\times\frac{\sqrt{x+2}+2}{\sqrt{x+2}+2}$

$$=\frac{(x^2-3-1)(\sqrt{x+2}+2)}{(x+2-4)(\sqrt{x^2-3}+1)}$$
$$=\frac{(x^2-4)(\sqrt{x+2}+2)}{(x-2)(\sqrt{x^2-3}+1)}$$
$$=\frac{\cancel{(x-2)}(x+2)(\sqrt{x+2}+2)}{\cancel{(x-2)}(\sqrt{x^2-3}+1)}$$
$$=\frac{(x+2)(\sqrt{x+2}+2)}{(\sqrt{x^2-3}+1)}$$

យើងបាន $\lim\limits_{x\to 2}\frac{\sqrt{x^2-3}-1}{\sqrt{x+2}-2}=\lim\limits_{x\to 2}\frac{(x+2)(\sqrt{x+2}+2)}{(\sqrt{x^2-3}+1)}$

$$=\frac{(2+2)(\sqrt{2+2}+2)}{(\sqrt{2^2-3}+1)}$$
$$=\frac{4\times 4}{2}=8$$

ដូចនេះ៖ $\boxed{\lim\limits_{x\to 2}\frac{\sqrt{x^2-3}-1}{\sqrt{x+2}-2}=8}$

គ. $\lim\limits_{x\to 1}\frac{x+1-\sqrt{x^2+3}}{\sqrt{x}-1}$, (គុណកន្សោមឆ្លាស់អង្គទាំងពីរ) យើងមាន៖

$$\frac{x+1-\sqrt{x^2+3}}{\sqrt{x}-1}=\frac{x+1-\sqrt{x^2+3}}{\sqrt{x}-1}\times\frac{x+1+\sqrt{x^2+3}}{x+1+\sqrt{x^2+3}}\times\frac{\sqrt{x}+1}{\sqrt{x}+1}$$
$$=\frac{[(x+1)^2-(x^2+3)](\sqrt{x}+1)}{(x-1)(x+1+\sqrt{x^2+3})}$$
$$=\frac{2(x-1)(\sqrt{x}+1)}{(x-1)(x+1+\sqrt{x^2+3})}$$
$$=\frac{2\cancel{(x-1)}(\sqrt{x}+1)}{\cancel{(x-1)}(x+1+\sqrt{x^2+3})}$$
$$=\frac{2(\sqrt{x}+1)}{x+1+\sqrt{x^2+3}}$$
$$=\frac{2(\sqrt{1}+1)}{1+1+\sqrt{1^2+3}}$$
$$=1$$

ដូចនេះ៖ $\boxed{\lim\limits_{x\to 1}\frac{x+1-\sqrt{x^2+3}}{\sqrt{x}-1}=1}$

ឃ. $\lim\limits_{x\to 3}\frac{x^2-9}{x-1-\sqrt{x+1}}$, (គុណកន្សោមឆ្លាស់អង្គទាំងពីរ)

យើងបាន $\frac{x^2-9}{x-1-\sqrt{x+1}}=\frac{x^2-9}{x-1-\sqrt{x+1}}\times\frac{x-1+\sqrt{x+1}}{x-1+\sqrt{x+1}}$

$$=\frac{(x^2-9)(x-1+\sqrt{x+1})}{(x-1)^2-(x+1)}$$
$$=\frac{\cancel{(x-3)}(x+3)(x-1+\sqrt{x+1})}{x\cancel{(x-3)}}$$
$$=\frac{(x+3)(x-1+\sqrt{x+1})}{x}$$
$$=\frac{(3+3)(3-1+\sqrt{3+1})}{3}$$
$$=8$$

ដូចនេះ៖ $\boxed{\lim\limits_{x\to 3}\frac{x^2-9}{x-1-\sqrt{x+1}}=8}$

៣.២ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន រាង $A-\sqrt{B}$

សម្គាល់

ប្រសិនបើកន្សោមរាង $\frac{A-\sqrt{B}}{F(x)}$ ឬ $\frac{G(x)}{A-\sqrt{B}}$ យើងត្រូវ គុណនឹងកន្សោមឆ្លាស់របស់វាគឺ៖ $A+\sqrt{B}$ យើងបាន៖

$(A-\sqrt{B})(A+\sqrt{B}) = A^2 - B$ ឬ $(A-\sqrt{B}) = \frac{A^2-B}{A+\sqrt{B}}$ ។

លំហាត់គំរូ ១២

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 0}\frac{2-\sqrt{x+4}}{x}$

ខ. $\lim\limits_{x\to 2}\frac{-3+\sqrt{x+7}}{x-2}$

គ. $\lim\limits_{x\to 3}\frac{x-\sqrt{2x+3}}{x-3}$

ឃ. $\lim\limits_{x\to 1}\frac{(x-1)^2}{x-\sqrt{2x-1}}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

៣.៣ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន រាង $\sqrt{A}-\sqrt{B}$

សម្គាល់

ប្រសិនបើកន្សោមរាង $\frac{\sqrt{A}-\sqrt{B}}{F(x)}$ ឬ $\frac{G(x)}{\sqrt{A}-\sqrt{B}}$ យើងត្រូវ គុណនឹងកន្សោមឆ្លាស់របស់វាគឺ៖ $\sqrt{A}+\sqrt{B}$ យើងបាន៖
$(\sqrt{A}-\sqrt{B})(\sqrt{A}+\sqrt{B}) = A-B$ ឬ $\sqrt{A}-\sqrt{B} = \frac{A-B}{\sqrt{A}+\sqrt{B}}$ ។

លំហាត់គំរូ ១៣

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 4}\frac{\sqrt{2x+1}-3}{\sqrt{x-2}-\sqrt{2}}$

ខ. $\lim\limits_{x\to 0}\frac{\sqrt{1+x}+\sqrt{x+4}-3}{x}$

គ. $\lim\limits_{x\to 1}\frac{\sqrt{x+3}-\sqrt{3x+1}}{\sqrt{x}-1}$

ឃ. $\lim\limits_{x\to 1}\frac{\sqrt{x^2+3x}-\sqrt{3x+1}}{\sqrt{x}-1}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 4}\frac{\sqrt{2x+1}-3}{\sqrt{x-2}-\sqrt{2}}$; (មានរាងមិនកំណត់ $\frac{0}{0}$)

$$\begin{aligned}
\lim_{x\to 4}\frac{\sqrt{2x+1}-3}{\sqrt{x-2}-\sqrt{2}} &= \lim_{x\to 4}\left[\frac{\sqrt{2x+1}-3}{\sqrt{x-2}-\sqrt{2}}\times\frac{\sqrt{2x+1}+3}{\sqrt{2x+1}+3}\times\frac{\sqrt{x-2}+\sqrt{2}}{\sqrt{x-2}+\sqrt{2}}\right]\\
&= \lim_{x\to 4}\frac{(2x+1-3^2)(\sqrt{x-2}+\sqrt{2})}{(x-2-2)(\sqrt{2x+1}+3)}\\
&= \lim_{x\to 4}\frac{2\cancel{(x-4)}(\sqrt{x-2}+\sqrt{2})}{\cancel{(x-4)}(\sqrt{2x+1}+3)}\\
&= \lim_{x\to 4}\frac{2(\sqrt{x-2}+\sqrt{2})}{(\sqrt{2x+1}+3)}\\
&= \frac{2\times 2\sqrt{2}}{3+3} = \frac{2\sqrt{2}}{3}
\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to4}\frac{\sqrt{2x+1}-3}{\sqrt{x-2}-\sqrt{2}}=\frac{2\sqrt{2}}{3}}$

ខ. $\lim\limits_{x\to0}\frac{\sqrt{1+x}+\sqrt{x+4}-3}{x}$; (មានរាងមិនកំណត់ $\frac{0}{0}$)

ដោយ $\lim\limits_{x\to0}\frac{\sqrt{1+x}+\sqrt{x+4}-3}{x}=\lim\limits_{x\to0}\frac{\sqrt{1+x}-1+\sqrt{x+4}-2}{x}$

អាចសរសេរទៅជា:

$\lim\limits_{x\to0}\frac{\sqrt{1+x}-1+\sqrt{x+4}-2}{x}=\lim\limits_{x\to0}\frac{\sqrt{1+x}-1}{x}+\lim\limits_{x\to0}\frac{\sqrt{x+4}-2}{x}$

• ករណី $\lim\limits_{x\to0}\frac{\sqrt{1+x}-1}{x}$

$$=\lim_{x\to0}\frac{(\sqrt{1+x}-1)(\sqrt{1+x}+1)}{x(\sqrt{1+x}+1)}$$
$$=\lim_{x\to0}\frac{1+x-1}{x(\sqrt{1+x}+1)}$$
$$=\lim_{x\to0}\frac{\cancel{x}}{\cancel{x}(\sqrt{1+x}+1)}$$
$$=\lim_{x\to0}\frac{1}{(\sqrt{1+x}+1)}$$
$$=\frac{1}{(\sqrt{1+0}+1)}=\frac{1}{2}$$

• ករណី $\lim\limits_{x\to0}\frac{\sqrt{x+4}-2}{x}$

$$=\lim_{x\to0}\frac{(\sqrt{x+4}-2)(\sqrt{x+4}+2)}{x(\sqrt{x+4}+2)}$$
$$=\lim_{x\to0}\frac{x+4-4}{x(\sqrt{x+4}+2)}$$
$$=\lim_{x\to0}\frac{1}{(\sqrt{x+4}+2)}$$
$$=\frac{1}{(\sqrt{0+4}+2)}=\frac{1}{2+2}=\frac{1}{4}$$

នាំឱ្យ យើងបាន៖ $\lim\limits_{x\to0}\frac{\sqrt{1+x}-1}{x}+\lim\limits_{x\to0}\frac{\sqrt{x+4}-2}{x}=\frac{1}{2}+\frac{1}{4}=\frac{3}{4}$

ដូចនេះ $\boxed{\lim\limits_{x\to0}\frac{\sqrt{1+x}+\sqrt{x+4}-3}{x}=\frac{3}{4}}$

គ. $\lim\limits_{x\to1}\frac{\sqrt{x+3}-\sqrt{3x+1}}{\sqrt{x}-1}$; (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to1}\frac{(\sqrt{x+3}-\sqrt{3x+1})(\sqrt{x+3}+\sqrt{3x+1})(\sqrt{x}-1)}{(\sqrt{x}-1)(\sqrt{x+3}+\sqrt{3x+1})(\sqrt{x}-1)}$$
$$=\lim_{x\to1}\frac{[(x+3)-(3x+1)](\sqrt{x}-1)}{(x-1)(\sqrt{x+3}+\sqrt{3x+1})}$$
$$=\lim_{x\to1}\frac{(x+3-3x-1)(\sqrt{x}-1)}{(x-1)(\sqrt{x+3}+\sqrt{3x+1})}$$
$$=\lim_{x\to1}\frac{(2-2x)(\sqrt{x}-1)}{(x-1)(\sqrt{x+3}+\sqrt{3x+1})}$$
$$=\lim_{x\to1}\frac{-2\cancel{(x-1)}(\sqrt{x}-1)}{\cancel{(x-1)}(\sqrt{x+3}+\sqrt{3x+1})}$$
$$=\lim_{x\to1}\frac{-2(\sqrt{x}-1)}{(\sqrt{x+3}+\sqrt{3x+1})}$$
$$=\frac{-2(\sqrt{1}-1)}{(\sqrt{1+3}+\sqrt{3\times1+1})}$$
$$=\frac{-2\times\sqrt{0}}{2+2}=0$$

ដូចនេះ $\boxed{\lim\limits_{x\to1}\frac{\sqrt{x+3}-\sqrt{3x+1}}{\sqrt{x}-1}=0}$

ឃ. $\lim\limits_{x\to1}\frac{\sqrt{x^2+3x}-\sqrt{3x+1}}{\sqrt{x}-1}$; (មានរាងមិនកំណត់ $\frac{0}{0}$)

$$=\lim_{x\to1}\frac{(\sqrt{x^2+3x}-\sqrt{3x+1})(\sqrt{x^2+3x}+\sqrt{3x+1})(\sqrt{x}+1)}{(\sqrt{x}-1)(\sqrt{x^2+3x}+\sqrt{3x+1})(\sqrt{x}+1)}$$
$$=\lim_{x\to1}\frac{[(x^2+3x)-(3x+1)](\sqrt{x}+1)}{(x-1)(\sqrt{x^2+3x}+\sqrt{3x+1})}$$
$$=\lim_{x\to1}\frac{(x^2+3x-3x-1)(\sqrt{x}+1)}{(x-1)(\sqrt{x^2+3x}+\sqrt{3x+1})}$$
$$=\lim_{x\to1}\frac{\cancel{(x-1)}(x+1)(\sqrt{x}+1)}{\cancel{(x-1)}(\sqrt{x^2+3x}+\sqrt{3x+1})}$$
$$=\lim_{x\to1}\frac{(x+1)(\sqrt{x}+1)}{\sqrt{x^2+3x}+\sqrt{3x+1}}$$
$$=\frac{(1+1)(\sqrt{1}+1)}{\sqrt{1^2+3\times1}+\sqrt{3\times1+1}}=1$$

ដូចនេះ $\boxed{\lim\limits_{x\to1}\frac{\sqrt{x^2+3x}-\sqrt{3x+1}}{\sqrt{x}-1}=1}$

៣.៤ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន រាង $\sqrt[3]{A}-B$

សម្គាល់

ប្រសិនបើកន្សោមមានរាង $\frac{\sqrt[3]{A}-B}{F(x)}$ ឬ $\frac{G(x)}{\sqrt[3]{A}-B}$ យើងត្រូវគុណនឹងកន្សោមឆ្លាស់របស់វាគឺ $(\sqrt[3]{A^2}+B\sqrt[3]{A}+B^2)$ ។ យើងបាន $(\sqrt[3]{A}-B)(\sqrt[3]{A^2}+B\sqrt[3]{A}+B^2)=A-B^3$ ឬ $\sqrt[3]{A}-B=\frac{A-B^3}{\sqrt[3]{A^2}+B\sqrt[3]{A}+B^2}$

លំហាត់គំរូ ១៤

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to8}\frac{\sqrt[3]{x}-2}{x-8}$

ខ. $\lim\limits_{x\to1}\frac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}$

គ. $\lim\limits_{x\to-1}\frac{\sqrt[3]{x}+1}{\sqrt{x^2+3}-2}$

ឃ. $\lim\limits_{x\to0}\frac{\sqrt[3]{1+x^2}-1}{x^2}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 8}\frac{\sqrt[3]{x}-2}{x-8}$; រាងមិនកំណត់ $\frac{0}{0}$

$$\begin{aligned}\lim_{x\to 8}\frac{\sqrt[3]{x}-2}{x-8}&=\lim_{x\to 8}\frac{(\sqrt[3]{x}-2)(\sqrt[3]{x^2}+2\sqrt[3]{x}+4)}{(x-8)(\sqrt[3]{x^2}+2\sqrt[3]{x}+4)}\\&=\lim_{x\to 8}\frac{\cancel{x-8}}{\cancel{(x-8)}(\sqrt[3]{x^2}+2\sqrt[3]{x}+4)}\\&=\lim_{x\to 8}\frac{1}{(\sqrt[3]{x^2}+2\sqrt[3]{x}+4)}\\&=\frac{1}{(\sqrt[3]{8^2}+2\sqrt[3]{8}+4)}\\&=\frac{1}{12}\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to 8}\frac{\sqrt[3]{x}-2}{x-8}=\frac{1}{12}}$

ខ. $\lim\limits_{x\to 1}\frac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}$; រាងមិនកំណត់ $\frac{0}{0}$

$$\begin{aligned}&=\lim_{x\to 1}\frac{(\sqrt[3]{x}-1)(\sqrt[3]{x^2}+\sqrt[3]{x}+1)(\sqrt[3]{(4x+4)^2}+2\sqrt[3]{4x+4}+4)}{(\sqrt[3]{4x+4}-2)(\sqrt[3]{x^2}+\sqrt[3]{x}+1)(\sqrt[3]{(4x+4)^2}+2\sqrt[3]{4x+4}+4)}\\&=\lim_{x\to 1}\frac{(x-1)(\sqrt[3]{(4x+4)^2}+2\sqrt[3]{4x+4}+4)}{(4x+4-8)(\sqrt[3]{x^2}+\sqrt[3]{x}+1)}\\&=\lim_{x\to 1}\frac{(x-1)(\sqrt[3]{(4x+4)^2}+2\sqrt[3]{4x+4}+4)}{(4x-4)(\sqrt[3]{x^2}+\sqrt[3]{x}+1)}\\&=\lim_{x\to 1}\frac{\cancel{(x-1)}(\sqrt[3]{(4x+4)^2}+2\sqrt[3]{4x+4}+4)}{4\cancel{(x-1)}(\sqrt[3]{x^2}+\sqrt[3]{x}+1)}\\&=\lim_{x\to 1}\frac{(\sqrt[3]{(4x+4)^2}+2\sqrt[3]{4x+4}+4)}{4(\sqrt[3]{x^2}+\sqrt[3]{x}+1)}\\&=\frac{(\sqrt[3]{(4+4)^2}+2\sqrt[3]{4\times 1+4}+4)}{4(\sqrt[3]{1^2}+\sqrt[3]{1}+1)}=1\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to 1}\frac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}=1}$

គ. $\lim\limits_{x\to -1}\frac{\sqrt[3]{x}+1}{\sqrt{x^2+3}-2}$; រាងមិនកំណត់ $\frac{0}{0}$

$$\begin{aligned}\lim_{x\to -1}\frac{\sqrt[3]{x}+1}{\sqrt{x^2+3}-2}&=\lim_{x\to -1}\frac{(\sqrt[3]{x}+1)(\sqrt[3]{x^2}-\sqrt[3]{x}+1)(\sqrt{x^2+3}+2)}{(\sqrt{x^2+3}-2)(\sqrt[3]{x^2}-\sqrt[3]{x}+1)(\sqrt{x^2+3}+2)}\\&=\lim_{x\to -1}\frac{(x+1)(\sqrt{x^2+3}+2)}{(x^2+3-4)(\sqrt[3]{x^2}-\sqrt[3]{x}+1)}\\&=\lim_{x\to -1}\frac{(x+1)(\sqrt{x^2+3}+2)}{(x^2-1)(\sqrt[3]{x^2}-\sqrt[3]{x}+1)}\\&=\lim_{x\to -1}\frac{(\sqrt{x^2+3}+2)}{(x-1)(\sqrt[3]{x^2}-\sqrt[3]{x}+1)}\\&=\frac{\sqrt{(-1)^2+3}+2}{(-1-1)(\sqrt[3]{(-1)^2}-\sqrt[3]{-1}+1)}\\&=-\frac{2}{3}\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to -1}\frac{\sqrt[3]{x}+1}{\sqrt{x^2+3}-2}=-\frac{2}{3}}$

ឃ. $\lim\limits_{x\to 0}\frac{\sqrt[3]{1+x^2}-1}{x^2}$; រាងមិនកំណត់ $\frac{0}{0}$

$$\begin{aligned}\lim_{x\to 0}\frac{\sqrt[3]{1+x^2}-1}{x^2}&=\lim_{x\to 0}\frac{(\sqrt[3]{1+x^2}-1)(\sqrt[3]{(1+x^2)^2}+\sqrt[3]{1+x^2}+1)}{x^2(\sqrt[3]{(1+x^2)^2}+\sqrt[3]{1+x^2}+1)}\\&=\lim_{x\to 0}\frac{(1+x^2-1)}{x^2(\sqrt[3]{(1+x^2)^2}+\sqrt[3]{1+x^2}+1)}\\&=\lim_{x\to 0}\frac{\cancel{x^2}}{\cancel{x^2}\left(\sqrt[3]{(1+x^2)^2}+\sqrt[3]{1+x^2}+1\right)}\\&=\lim_{x\to 0}\frac{1}{(\sqrt[3]{(1+x^2)^2}+\sqrt[3]{1+x^2}+1)}\\&=\frac{1}{(\sqrt[3]{(1+0^2)^2}+\sqrt[3]{1+0^2}+1)}\\&=\frac{1}{3}\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\frac{\sqrt[3]{1+x^2}-1}{x^2}=\frac{1}{3}}$

៣.៥ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន រាង $A-\sqrt[3]{B}$

សម្គាល់

ប្រសិនបើកន្សោមមានរាង $\frac{A-\sqrt[3]{B}}{F(x)}$ ឬ $\frac{G(x)}{A-\sqrt[3]{B}}$ យើងត្រូវគុណនឹងកន្សោមឆ្លាស់របស់វាគឺ $A^2+A\sqrt[3]{B}+\sqrt[3]{B^2}$ ។ យើងបាន $(A-\sqrt[3]{B})(A^2+A\sqrt[3]{B}+\sqrt[3]{B^2})=A^3-B$ ឬ $A-\sqrt[3]{B}=\frac{A^3-B}{A^2+A\sqrt[3]{B}+\sqrt[3]{B^2}}$ ។

លំហាត់គំរូ ១៥

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 2}\frac{x^3-\sqrt{x^2+60}}{x^2-\sqrt[3]{x^2+60}}$

ខ. $\lim\limits_{x\to 2}\frac{x-\sqrt[3]{x^2+4}}{x-2}$

គ. $\lim\limits_{x\to 0}\frac{1-\sqrt[3]{1-x}}{3x}$

ឃ. $\lim\limits_{x\to 3}\frac{x-3}{x-1-\sqrt[3]{x^2-1}}$

មេរៀនទី ២ វិធីសាស្ត្រក្នុងការគណនា

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 2}\frac{x^3-\sqrt{x^2+60}}{x^2-\sqrt[3]{x^2+60}}$; រាងមិនកំណត់ $\frac{0}{0}$

$$
\begin{aligned}
&= \lim_{x\to 2}\frac{(x^3-\sqrt{x^2+60})(x^3+\sqrt{x^2+60})[x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2}]}{(x^2-\sqrt[3]{x^2+60})(x^3+\sqrt{x^2+60})[x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2}]}\\
&= \lim_{x\to 2}\frac{\cancel{(x^6-x^2-60)}[x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2}]}{\cancel{(x^6-x^2-60)}(x^3+\sqrt{x^2+60})}\\
&= \lim_{x\to 2}\frac{x^4+x^2\sqrt[3]{x^2+60}+\sqrt[3]{(x^2+60)^2}}{x^3+\sqrt{x^2+60}}\\
&= \frac{2^4+2^2\sqrt[3]{2^2+60}+\sqrt[3]{(2^2+60)^2}}{(2^3+\sqrt{2^2+60})}\\
&= \frac{16+16+16}{16}\\
&= 3
\end{aligned}
$$

ដូចនេះ $\boxed{\lim\limits_{x\to 2}\frac{x^3-\sqrt{x^2+60}}{x^2-\sqrt[3]{x^2+60}}=3}$

ខ. $\lim\limits_{x\to 2}\frac{x-\sqrt[3]{x^2-4}}{x-2}$; រាងមិនកំណត់ $\frac{0}{0}$

$$
\begin{aligned}
\lim_{x\to 2}\frac{x-\sqrt[3]{x^2-4}}{x-2} &= \lim_{x\to 2}\frac{(x-\sqrt[3]{x^2+4})[x^2+x\sqrt[3]{x^2+4}+\sqrt[3]{(x^2+4)^2}]}{(x-2)[x^2+x\sqrt[3]{x^2+4}+\sqrt[3]{(x^2+4)^2}]}\\
&= \lim_{x\to 2}\frac{x^3-x^2-4}{(x-2)[x^2+x\sqrt[3]{x^2+4}+\sqrt[3]{(x^2+4)^2}]}\\
&= \lim_{x\to 2}\frac{(x^3-2x^2)+(x^2-4)}{(x-2)[x^2+x\sqrt[3]{x^2+4}+\sqrt[3]{(x^2+4)^2}]}\\
&= \lim_{x\to 2}\frac{\cancel{(x-2)}(x^2+x+2)}{\cancel{(x-2)}[x^2+x\sqrt[3]{x^2+4}+\sqrt[3]{(x^2+4)^2}]}\\
&= \lim_{x\to 2}\frac{x^2+x+2}{x^2+x\sqrt[3]{x^2+4}+\sqrt[3]{(x^2+4)^2}}\\
&= \frac{2^2+2+2}{2^2+2\sqrt[3]{2^2+4}+\sqrt[3]{(2^2+4)^2}}\\
&= \frac{2}{3}
\end{aligned}
$$

ដូចនេះ $\boxed{\lim\limits_{x\to 2}\frac{x-\sqrt[3]{x^2-4}}{x-2}=\frac{2}{3}}$

គ. $\lim\limits_{x\to 0}\frac{1-\sqrt[3]{1-x}}{3x}$; រាងមិនកំណត់ $\frac{0}{0}$

$$
\begin{aligned}
\lim_{x\to 0}\frac{1-\sqrt[3]{1-x}}{3x} &= \lim_{x\to 0}\frac{(1-\sqrt[3]{1-x})[1+\sqrt[3]{1-x}+\sqrt[3]{(1-x)^2}]}{3x[1+\sqrt[3]{1-x}+\sqrt[3]{(1-x)^2}]}\\
&= \lim_{x\to 0}\frac{1-1+x}{3x[1+\sqrt[3]{1-x}+\sqrt[3]{(1-x)^2}]}\\
&= \lim_{x\to 0}\frac{\cancel{x}}{3\cancel{x}[1+\sqrt[3]{1-x}+\sqrt[3]{(1-x)^2}]}\\
&= \lim_{x\to 0}\frac{1}{3[1+\sqrt[3]{1-x}+\sqrt[3]{(1-x)^2}]}\\
&= \frac{1}{3[1+\sqrt[3]{1-0}+\sqrt[3]{(1-0)^2}]}=\frac{1}{9}
\end{aligned}
$$

ដូចនេះ $\boxed{\lim\limits_{x\to 0}\frac{1-\sqrt[3]{1-x}}{3x}=\frac{1}{9}}$

ឃ. $\lim\limits_{x\to 3}\frac{x-3}{x-1-\sqrt[3]{x^2-1}}$; រាងមិនកំណត់ $\frac{0}{0}$

យើងមាន $\lim\limits_{x\to 3}\frac{x-3}{x-1-\sqrt[3]{x^2-1}}$ អាចសរសេរទៅជា៖ $\lim\limits_{x\to 3}\frac{x-3}{(x-1)-(\sqrt[3]{x^2-1})}$

$$
\begin{aligned}
&= \lim_{x\to 3}\frac{(x-3)[(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}{[(x-1)-(\sqrt[3]{x^2-1})][(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}\\
&= \lim_{x\to 3}\frac{(x-3)[(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}{(x-1)^3-(x^2-1)}\\
&= \lim_{x\to 3}\frac{(x-3)[(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}{(x-1)(x^2-2x+1)-(x-1)(x+1)}\\
&= \lim_{x\to 3}\frac{(x-3)[(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}{(x-1)[(x^2-2x+1)-(x+1)]}\\
&= \lim_{x\to 3}\frac{(x-3)[(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}{(x-1)(x^2-2x+1-x-1)}\\
&= \lim_{x\to 3}\frac{(x-3)[(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}{(x-1)(x^2-3x)}\\
&= \lim_{x\to 3}\frac{\cancel{(x-3)}[(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}]}{x(x-1)\cancel{(x-3)}}\\
&= \lim_{x\to 3}\frac{(x-1)^2+(x-1)(\sqrt[3]{x^2-1})+\sqrt[3]{(x^2-1)^2}}{x(x-1)}\\
&= \frac{(3-1)^2+(3-1)(\sqrt[3]{3^2-1})+\sqrt[3]{(3^2-1)^2}}{3(3-1)}\\
&= 2
\end{aligned}
$$

ដូចនេះ $\boxed{\lim\limits_{x\to 3}\frac{x-3}{x-1-\sqrt[3]{x^2-1}}=2}$

៣.៦ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន រាង $\sqrt[3]{A}-\sqrt[3]{B}$

⚠ សម្គាល់

ប្រសិនបើកន្សោមមានរាង $\frac{\sqrt[3]{A}-\sqrt[3]{B}}{F(x)}$ ឬ $\frac{G(x)}{\sqrt[3]{A}-\sqrt[3]{B}}$ យើងត្រូវគុណនឹងកន្សោមឆ្លាស់របស់វាគឺ $\sqrt[3]{A^2}+\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2}$ ។ យើងបាន $(\sqrt[3]{A}-\sqrt[3]{B})(\sqrt[3]{A^2}+\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2})=A-B$ ឬ $\sqrt[3]{A}-\sqrt[3]{B}=\frac{A-B}{\sqrt[3]{A^2}+\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2}}$

លំហាត់គំរូ ១៦

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to1}\frac{\sqrt[3]{x-2}+\sqrt[3]{1-x+x^2}}{x^2-1}$

ខ. $\lim\limits_{x\to3}\frac{\sqrt[3]{x^2-1}-\sqrt[3]{x+5}}{x-3}$

គ. $\lim\limits_{x\to1}\frac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{(x-1)^2}$

ឃ. $\lim\limits_{x\to2}\frac{\sqrt[3]{x^2+4}-\sqrt[3]{x+6}}{x-2}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to1}\frac{\sqrt[3]{x-2}+\sqrt[3]{1-x+x^2}}{x^2-1}$; រាងមិនកំណត់ $\frac{0}{0}$

យើងមាន $\lim\limits_{x\to1}\frac{\sqrt[3]{x-2}+\sqrt[3]{1-x+x^2}}{x^2-1}$

អាចសរសេរទៅជា: $\lim\limits_{x\to1}\frac{(\sqrt[3]{x-2}+1)+(\sqrt[3]{1-x+x^2}-1)}{x^2-1}$

$=\lim\limits_{x\to1}\frac{\sqrt[3]{x-2}+1}{x^2-1}+\lim\limits_{x\to1}\frac{\sqrt[3]{1-x+x^2}-1}{x^2-1}$

- ករណី $\lim\limits_{x\to1}\frac{\sqrt[3]{x-2}+1}{x^2-1}$

$=\lim\limits_{x\to1}\frac{(\sqrt[3]{x-2}+1)[\sqrt[3]{(x-2)^2}-\sqrt[3]{x-2}+1]}{(x^2-1)[\sqrt[3]{(x-2)^2}-\sqrt[3]{x-2}+1]}$

$=\lim\limits_{x\to1}\frac{x-2+1}{(x^2-1)[\sqrt[3]{(x-2)^2}-\sqrt[3]{x-2}+1]}$

$=\lim\limits_{x\to1}\frac{\cancel{x-1}}{\cancel{(x-1)}(x+1)[\sqrt[3]{(x-2)^2)}-\sqrt[3]{x-2}+1]}$

$=\lim\limits_{x\to1}\frac{1}{(x+1)[\sqrt[3]{(x-2)^2)}-\sqrt[3]{x-2}+1]}$

$=\lim\limits_{x\to1}\frac{1}{(1+1)[\sqrt[3]{(1-2)^2}-\sqrt[3]{1-2}+1]}$

$=\frac{1}{6}$

- ករណី $\lim\limits_{x\to1}\frac{\sqrt[3]{1-x+x^2}-1}{x^2-1}$

$=\lim\limits_{x\to1}\frac{(\sqrt[3]{1-x+x^2}-1)[\sqrt[3]{(1-x+x^2)^2}+\sqrt[3]{1-x+x^2}+1]}{(x^2-1)[\sqrt[3]{(1-x+x^2)^2}+\sqrt[3]{1-x+x^2}+1]}$

$=\lim\limits_{x\to1}\frac{1-x+x^2-1}{(x^2-1)[\sqrt[3]{(1-x+x^2)^2}+\sqrt[3]{1-x+x^2}+1]}$

$=\lim\limits_{x\to1}\frac{x^2-x}{(x^2-1)[\sqrt[3]{(1-x+x^2)^2}+\sqrt[3]{1-x+x^2}+1]}$

$=\lim\limits_{x\to1}\frac{x\cancel{(x-1)}}{\cancel{(x-1)}(x+1)[\sqrt[3]{(1-x+x^2)^2}+\sqrt[3]{1-x+x^2}+1]}$

$=\lim\limits_{x\to1}\frac{x}{(x+1)[\sqrt[3]{(1-x+x^2)^2}+\sqrt[3]{1-x+x^2}+1]}$

$=\frac{x}{(1+1)[\sqrt[3]{(1-1+1^2)^2}+\sqrt[3]{1-1+1^2}+1]}$

$=\frac{1}{6}$

យើងបាន៖

$\lim\limits_{x\to1}\frac{\sqrt[3]{x-2}+1}{x^2-1}+\lim\limits_{x\to1}\frac{\sqrt[3]{1-x+x^2}-1}{x^2-1}=\frac{1}{6}+\frac{1}{6}=\frac{1}{3}$

ដូចនេះ $\boxed{\lim\limits_{x\to1}\frac{\sqrt[3]{x-2}+\sqrt[3]{1-x+x^2}}{x^2-1}=\frac{1}{3}}$

ខ. $\lim\limits_{x\to3}\frac{\sqrt[3]{x^2-1}-\sqrt[3]{x+5}}{x-3}$; រាងមិនកំណត់ $\frac{0}{0}$

$=\lim\limits_{x\to3}\frac{(\sqrt[3]{x^2-1}-\sqrt[3]{x+5})[\sqrt[3]{(x^2-1)^2}+(\sqrt[3]{x^2-1})(\sqrt[3]{x+5})+\sqrt[3]{(x+5)^2}]}{(x-3)[\sqrt[3]{(x^2-1)^2}+(\sqrt[3]{x^2-1})(\sqrt[3]{x+5})+\sqrt[3]{(x+5)^2}]}$

$=\lim\limits_{x\to3}\frac{(x^2-1)-(x+5)}{(x-3)[\sqrt[3]{(x^2-1)^2}+(\sqrt[3]{x^2-1})(\sqrt[3]{x+5})+\sqrt[3]{(x+5)^2}]}$

$=\lim\limits_{x\to3}\frac{x^2-1-x-5}{(x-3)[\sqrt[3]{(x^2-1)^2}+(\sqrt[3]{x^2-1})(\sqrt[3]{x+5})+\sqrt[3]{(x+5)^2}]}$

$=\lim\limits_{x\to3}\frac{x^2-x-6}{(x-3)[\sqrt[3]{(x^2-1)^2}+(\sqrt[3]{x^2-1})(\sqrt[3]{x+5})+\sqrt[3]{(x+5)^2}]}$

$=\lim\limits_{x\to3}\frac{(x+2)\cancel{(x-3)}}{\cancel{(x-3)}[\sqrt[3]{(x^2-1)^2}+(\sqrt[3]{x^2-1})(\sqrt[3]{x+5})+\sqrt[3]{(x+5)^2}]}$

$=\lim\limits_{x\to3}\frac{x+2}{\sqrt[3]{(x^2-1)^2}+(\sqrt[3]{x^2-1})(\sqrt[3]{x+5})+\sqrt[3]{(x+5)^2}}$

$=\frac{3+2}{\sqrt[3]{(3^2-1)^2}+(\sqrt[3]{3^2-1})(\sqrt[3]{3+5})+\sqrt[3]{(3+5)^2}}=\frac{5}{12}$

ដូចនេះ $\boxed{\lim\limits_{x\to3}\frac{\sqrt[3]{x^2-1}-\sqrt[3]{x+5}}{x-3}=\frac{5}{12}}$

គ. $\lim\limits_{x\to1}\frac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{(x-1)^2}$; រាងមិនកំណត់ $\frac{0}{0}$

យើងមាន $\lim\limits_{x\to1}\frac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{(x-1)^2}$ អាចសរសេរទៅជា:

$$\lim_{x\to1}\frac{(\sqrt[3]{x}-1)^2}{(x-1)^2}=\lim_{x\to1}\frac{(\sqrt[3]{x}-1)^2(\sqrt[3]{x^2}+\sqrt[3]{x}+1)^2}{(x-1)^2(\sqrt[3]{x^2}+\sqrt[3]{x}+1)^2}$$

$$=\lim_{x\to1}\frac{[(\sqrt[3]{x}-1)(\sqrt[3]{x^2}+\sqrt[3]{x}+1)]^2}{(x-1)^2(\sqrt[3]{x^2}+\sqrt[3]{x}+1)^2}$$

$$=\lim_{x\to1}\frac{\cancel{(x-1)^2}}{\cancel{(x-1)^2}(\sqrt[3]{x^2}+\sqrt[3]{x}+1)^2}$$

$$=\lim_{x\to1}\frac{1}{(\sqrt[3]{x^2}+\sqrt[3]{x}+1)^2}$$

$$=\frac{1}{(\sqrt[3]{1^2}+\sqrt[3]{1}+1)^2}$$

$$=\frac{1}{9}$$

ដូចនេះ $\boxed{\lim\limits_{x\to1}\frac{\sqrt[3]{x^2}-2\sqrt[3]{x}+1}{(x-1)^2}=\frac{1}{9}}$

ឃ. $\lim\limits_{x\to2}\frac{\sqrt[3]{x^2+4}-\sqrt[3]{x+6}}{x-2}$; រាងមិនកំណត់ $\frac{0}{0}$

$=\lim\limits_{x\to2}\frac{\left(\sqrt[3]{x^2+4}-\sqrt[3]{x+6}\right)\left[\sqrt[3]{\left(x^2+4\right)^2}+\sqrt[3]{\left(x^2+4\right)(x+6)}+\sqrt[3]{(x+6)^2}\right]}{(x-2)\left[\sqrt[3]{\left(x^2+4\right)^2}+\sqrt[3]{\left(x^2+4\right)(x+6)}+\sqrt[3]{(x+6)^2}\right]}$

$=\lim\limits_{x\to2}\frac{\left(x^2+4\right)-(x+6)}{(x-2)\left[\sqrt[3]{\left(x^2+4\right)^2}+\sqrt[3]{\left(x^2+4\right)(x+6)}+\sqrt[3]{(x+6)^2}\right]}$

$=\lim\limits_{x\to2}\frac{x^2-x-2}{(x-2)\left[\sqrt[3]{\left(x^2+4\right)^2}+\sqrt[3]{\left(x^2+4\right)(x+6)}+\sqrt[3]{(x+6)^2}\right]}$

មេរៀនទី ២ វិធីសាស្ត្រក្នុងការគណនា

$$= \lim_{x\to 2}\frac{(x+1)(x-2)}{(x-2)\left[\sqrt[3]{(x^2+4)^2}+\sqrt[3]{(x^2+4)(x+6)}+\sqrt[3]{(x+6)^2}\right]}$$
$$= \lim_{x\to 2}\frac{x+1}{\sqrt[3]{(x^2+4)^2}+\sqrt[3]{(x^2+4)(x+6)}+\sqrt[3]{(x+6)^2}}$$
$$= \frac{2+1}{\sqrt[3]{(2^2+4)^2}+\sqrt[3]{(2^2+4)(2+6)}+\sqrt[3]{(2+6)^2}}$$
$$= \frac{3}{4+4+4}$$
$$= \frac{1}{4}$$

ដូចនេះ $\boxed{\lim_{x\to 2}\frac{\sqrt[3]{x^2+4}-\sqrt[3]{x+6}}{x-2}=\frac{1}{4}}$

៣.៧ របៀបគណនាលីមីតនៃអនុគមន៍អសនិទាន រាង $\sqrt[3]{A}+\sqrt[3]{B}$

សម្គាល់

ប្រសិនបើកន្សោមមានរាង $\frac{\sqrt[3]{A}+\sqrt[3]{B}}{F(x)}$ ឬ $\frac{G(x)}{\sqrt[3]{A}+\sqrt[3]{B}}$ យើងត្រូវគុណនឹងកន្សោមឆ្លាស់របស់វាគឺ $\sqrt[3]{A^2}-\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2}$ ។
យើងបាន $(\sqrt[3]{A}+\sqrt[3]{B})(\sqrt[3]{A^2}-\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2})=A+B$។

លំហាត់គំរូ ១៧

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to 0}\frac{\sqrt[3]{x^2+1}+\sqrt[3]{x^2-1}}{x^2}$

ខ. $\lim_{x\to -2}\frac{\sqrt[3]{x^2+4}+\sqrt[3]{4x}}{(x+2)^2}$

គ. $\lim_{x\to 4}\frac{\sqrt[3]{x+4}+\sqrt[3]{8-x^2}}{x-4}$

ឃ. $\lim_{x\to -2}\frac{\sqrt[3]{x^2-2x}+\sqrt[3]{x-6}}{x+2}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to 0}\frac{\sqrt[3]{x^2+1}+\sqrt[3]{x^2-1}}{x^2}$; រាងមិនកំណត់ $\frac{0}{0}$

$$= \lim_{x\to 0}\frac{(\sqrt[3]{x^2+1}+\sqrt[3]{x^2-1})[\sqrt[3]{(x^2+1)^2}-\sqrt[3]{(x^2+1)(x^2-1)}+\sqrt[3]{(x^2-1)^2}]}{x^2[\sqrt[3]{(x^2+1)^2}-\sqrt[3]{(x^2+1)(x^2-1)}+\sqrt[3]{(x^2-1)^2}]}$$
$$= \lim_{x\to 0}\frac{(x^2+1)+(x^2-1)}{x^2[\sqrt[3]{(x^2+1)^2}-\sqrt[3]{(x^2+1)(x^2-1)}+\sqrt[3]{(x^2-1)^2}]}$$
$$= \lim_{x\to 0}\frac{2\cancel{x^2}}{\cancel{x^2}[\sqrt[3]{(x^2+1)^2}-\sqrt[3]{(x^2+1)(x^2-1)}+\sqrt[3]{(x^2-1)^2}]}$$
$$= \lim_{x\to 0}\frac{2}{\sqrt[3]{(x^2+1)^2}-\sqrt[3]{(x^2+1)(x^2-1)}+\sqrt[3]{(x^2-1)^2}}$$
$$= \frac{2}{\sqrt[3]{(0^2+1)^2}-\sqrt[3]{(0^2+1)(0^2-1)}+\sqrt[3]{(0^2-1)^2}}$$
$$= \frac{2}{1+1+1}$$
$$= \frac{2}{3}$$

ដូចនេះ $\boxed{\lim_{x\to 0}\frac{\sqrt[3]{x^2+1}+\sqrt[3]{x^2-1}}{x^2}=\frac{2}{3}}$

ខ. $\lim_{x\to -2}\frac{\sqrt[3]{x^2+4}+\sqrt[3]{4x}}{(x+2)^2}$; រាងមិនកំណត់ $\frac{0}{0}$

$$= \lim_{x\to -2}\frac{(\sqrt[3]{x^2+4}+\sqrt[3]{4x})[\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}]}{(x+2)^2[\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}]}$$
$$= \lim_{x\to -2}\frac{x^2+4x+4}{(x+2)^2[\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}]}$$
$$= \lim_{x\to -2}\frac{\cancel{(x+2)^2}}{\cancel{(x+2)^2}[\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}]}$$
$$= \lim_{x\to -2}\frac{1}{\sqrt[3]{(x^2+4)^2}-\sqrt[3]{4x(x^2+4)}+\sqrt[3]{(4x)^2}}$$
$$= \frac{1}{\sqrt[3]{[(-2)^2+4]^2}-\sqrt[3]{4(-2)[(-2)^2+4]}+\sqrt[3]{[4(-2)]^2}}$$
$$= \frac{1}{4+4+4}$$
$$= \frac{1}{12}$$

ដូចនេះ $\boxed{\lim_{x\to -2}\frac{\sqrt[3]{x^2+4}+\sqrt[3]{4x}}{(x+2)^2}=\frac{1}{12}}$

គ. $\lim_{x\to 4}\frac{\sqrt[3]{x+4}+\sqrt[3]{8-x^2}}{x-4}$; រាងមិនកំណត់ $\frac{0}{0}$

$$= \lim_{x\to 4}\frac{(x+4)+(8-x^2)}{(x-4)[\sqrt[3]{(x+4)^2}+\sqrt[3]{(x+4)(8-x^2)}+\sqrt[3]{(x-x^2)^2}]}$$
$$= \lim_{x\to 4}\frac{-x^2+x+12}{(x-4)[\sqrt[3]{(x+4)^2}+\sqrt[3]{(x+4)(8-x^2)}+\sqrt[3]{(x-x^2)^2}]}$$
$$= \lim_{x\to 4}\frac{-(x+3)\cancel{(x-4)}}{\cancel{(x-4)}\sqrt[3]{(x+4)^2}+\sqrt[3]{(x+4)(8-x^2)}+\sqrt[3]{(x-x^2)^2}}$$
$$= \lim_{x\to 4}\frac{-(x+3)}{\sqrt[3]{(x+4)^2}+\sqrt[3]{(x+4)(8-x^2)}+\sqrt[3]{(x-x^2)^2}}$$
$$= \frac{-(4+3)}{\sqrt[3]{(4+4)^2}+\sqrt[3]{(4+4)(8-4^2)}+\sqrt[3]{(4-4^2)^2}}$$
$$= -\frac{7}{4+4+4}$$
$$= -\frac{7}{12}$$

ដូចនេះ $\boxed{\lim\limits_{x\to 4}\frac{\sqrt[3]{x+4}+\sqrt[3]{8-x^2}}{x-4}=-\frac{7}{12}}$

ឃ. $\lim\limits_{x\to -2}\frac{\sqrt[3]{x^2-2x}+\sqrt[3]{x-6}}{x+2}$; រាងមិនកំណត់ $\frac{0}{0}$

$$=\lim_{x\to -2}\frac{\left(\sqrt[3]{x^2-2x}+\sqrt[3]{x-6}\right)\left[\sqrt[3]{\left(x^2-2x\right)^2}-\sqrt[3]{\left(x^2-2x\right)(x-6)}+\sqrt[3]{(x-6)^2}\right]}{(x+2)\left[\sqrt[3]{\left(x^2-2x\right)^2}-\sqrt[3]{\left(x^2-2x\right)(x-6)}+\sqrt[3]{(x-6)^2}\right]}$$

$$=\lim_{x\to -2}\frac{\left(x^2-2x\right)+(x-6)}{(x+2)\left[\sqrt[3]{\left(x^2-2x\right)^2}-\sqrt[3]{\left(x^2-2x\right)(x-6)}+\sqrt[3]{(x-6)^2}\right]}$$

$$=\lim_{x\to -2}\frac{x^2-x-6}{(x+2)\left[\sqrt[3]{\left(x^2-2x\right)^2}-\sqrt[3]{\left(x^2-2x\right)(x-6)}+\sqrt[3]{(x-6)^2}\right]}$$

$$=\lim_{x\to -2}\frac{(x+2)(x-3)}{(x+2)\left[\sqrt[3]{\left(x^2-2x\right)^2}-\sqrt[3]{\left(x^2-2x\right)(x-6)}+\sqrt[3]{(x-6)^2}\right]}$$

$$=\lim_{x\to -2}\frac{x-3}{\sqrt[3]{\left(x^2-2x\right)^2}-\sqrt[3]{\left(x^2-2x\right)(x-6)}+\sqrt[3]{(x-6)^2}}$$

$$=\frac{-2-3}{\sqrt[3]{\left[(-2)^2-2(-2)\right]^2}-\sqrt[3]{\left[(-2)^2-2(-2)\right](-2-6)}+\sqrt[3]{(-2-6)^2}}$$

$$=-\frac{5}{12}$$

ដូចនេះ $\boxed{\lim\limits_{x\to -2}\frac{\sqrt[3]{x^2-2x}+\sqrt[3]{x-6}}{x+2}=-\frac{5}{12}}$

៤ របៀបគណនាលីមីតមិនកំណត់អនន្ត

1. $\lim\limits_{x\to\pm\infty}\frac{a}{x}=0\ ,\ \forall a\in\mathbb{R}$

2. $\lim\limits_{x\to\pm\infty}\frac{x}{a}=\pm\infty\ ,\ a\neq 0$

3. $\lim\limits_{x\to\pm\infty}ax^2=\begin{cases}+\infty\ , & \text{បើ } a>0\\ -\infty\ , & \text{បើ } a<0\end{cases}$

៤.១ របៀបគណនាលីមីតមិនកំណត់អនន្ត រាង $L=\frac{a_mx^m+a_{m-1}x^{m-1}\ldots+a_1x+a_0}{b_mx^m+b_{m-1}x^{m-1}\ldots+b_1x+b_0}$

សម្គាល់

- ដើម្បីគណនាលីមីតរាងប្រភេទនេះគេត្រូវ៖

១. ដាក់ x ដែលមានដឺក្រេខ្ពស់ជាងគេជាកត្តារួម

២. សម្រួលកត្តា x នោះចោល

៣. គណនាលីមីតនៃប្រភាគថ្មីដែលនៅសល់ក្រោយពីសម្រួលរួច។

លំហាត់គំរូ ១៨

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\infty}\frac{x^3+3x+2}{x^2+1}$

ខ. $\lim\limits_{x\to\infty}\frac{x^3+6x+7}{x^4+2x^2+6}$

គ. $\lim\limits_{x\to\infty}\frac{\sqrt[3]{x^3+2x-1}}{x+2}$

ឃ. $\lim\limits_{x\to\infty}\frac{2x^2-3x+4}{\sqrt{x^4+2x^2}}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\infty}\frac{x^3+3x+2}{x^2+1}$; រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន $\displaystyle\lim_{x\to\infty}\frac{x^3+3x+2}{x^2+1}=\lim_{x\to\infty}\frac{x^3(1+\frac{3}{x^2}+\frac{2}{x^3})}{x^2(1+\frac{1}{x^2})}$

$$=\lim_{x\to\infty}\frac{x(1+\frac{3}{x^2}+\frac{2}{x^3})}{(1+\frac{1}{x^2})}$$

$$=\frac{\infty(1+\frac{3}{\infty^2}+\frac{2}{\infty^3})}{1+\frac{1}{\infty^2}}$$

$$=\frac{\infty(1+0+0)}{1+0}$$

$$=\infty$$

ដូចនេះ $\boxed{\lim_{x\to\infty}\frac{x^3+3x+2}{x^2+1}=\infty}$

ខ. $\lim_{x\to\infty}\frac{x^3+6x+7}{x^4+2x^2+6}$; រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន $\displaystyle\lim_{x\to\infty}\frac{x^3+6x+7}{x^4+2x^2+6}=\lim_{x\to\infty}\frac{(1+\frac{6}{x^2}+\frac{7}{x^3})}{x(1+\frac{2}{x^2}+\frac{6}{x^4})}$

$$=\lim_{x\to\infty}\frac{1+\frac{6}{\infty^2}+\frac{7}{\infty^3}}{\infty(1+\frac{2}{\infty^2}+\frac{6}{\infty^4})}$$

$$=\frac{1+0+0}{\infty(1+0+0)}$$

$$=0$$

ដូចនេះ $\boxed{\lim_{x\to\infty}\frac{x^3+6x+7}{x^4+2x^2+6}=0}$

គ. $\lim_{x\to\infty}\frac{\sqrt[3]{x^3+2x-1}}{x+2}$; រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន $\displaystyle\lim_{x\to\infty}\frac{\sqrt[3]{x^3+2x-1}}{x+2}=\lim_{x\to\infty}\frac{\sqrt[3]{x^3(1+\frac{2}{x^2}-\frac{1}{x^3})}}{x(1+\frac{1}{x})}$

$$=\lim_{x\to\infty}\frac{\cancel{x}\sqrt[3]{(1+\frac{2}{x^2}-\frac{1}{x^3})}}{\cancel{x}(1+\frac{1}{x})}$$

$$=\lim_{x\to\infty}\frac{\sqrt[3]{1+\frac{2}{x^2}-\frac{1}{x^3}}}{(1+\frac{1}{x})}$$

$$=\frac{\sqrt[3]{1+\frac{2}{\infty^2}-\frac{1}{\infty^3}}}{1+\frac{1}{\infty}}$$

$$=1$$

ដូចនេះ $\boxed{\lim_{x\to\infty}\frac{\sqrt[3]{x^3+2x-1}}{x+2}=1}$

ឃ. $\lim_{x\to\infty}\frac{2x^2-3x+4}{\sqrt{x^4+2x^2}}$; រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន $\displaystyle\lim_{x\to\infty}\frac{2x^2-3x+4}{\sqrt{x^4+2x^2}}=\lim_{x\to\infty}\frac{x^2(2-\frac{3}{x}+\frac{4}{x^2})}{x^2\sqrt{(1+\frac{2}{x^2})}}$

$$=\lim_{x\to\infty}\frac{2-\frac{3}{x}+\frac{4}{x^2}}{\sqrt{1+\frac{2}{x^2}}}$$

$$=\frac{2-\frac{3}{\infty}+\frac{4}{\infty^2}}{\sqrt{(1+\frac{2}{\infty^2})}}$$

$$=2$$

ដូចនេះ $\boxed{\lim_{x\to\infty}\frac{2x^2-3x+4}{\sqrt{x^4+2}}=2}$

៥ របៀបគណនាលីមីតខិតជិតអនន្តចំពោះអនុគមន៍អសនិទាន

៥.១ របៀបគណនាលីមីតខិតជិតអនន្តអនុគមន៍អសនិទាន រាង $+\infty-\infty$

⚠ សម្គាល់

- ឧបមាថា $\lim_{x\to\infty}[(f(x)+g(x)]$ រាងមិនកំណត់ $+\infty-\infty$ បើ៖

១. បើកន្សោម $f(x)$ និង $g(x)$ ជាពហុធាគេទាញ x ដែលមានដឺក្រេខ្ពស់ជាងគេជាកត្តារួមរួចគណនាកន្សោមដែលសម្រួលរួច។

២. បើកន្សោម $f(x)$ និង $g(x)$ ជាប្រភាគសនិទានគេត្រូវតម្រូវភាគបែងរួម ហើយបំបែកជាផលគុណកត្តា រួចសម្រួលកត្តារួមចោល បន្ទាប់មកគណនាលីមីតថ្មី។

៣. បើកន្សោម $f(x)$ និង $g(x)$ ជាកន្សោមដែលមានរ៉ាឌីកាល់គេត្រូវប្រើរូបមន្ត៖

ក. $\sqrt{A}-B=\frac{A-B^2}{\sqrt{A}+B}$

ខ. $A-\sqrt{B}=\frac{A^2-B}{A+\sqrt{B}}$

គ. $\sqrt[3]{A}-B=\frac{A-B^3}{\sqrt[3]{A^2}+B\sqrt[3]{A}+B^2}$

ឃ. $A-\sqrt[3]{B}=\frac{A^3-B}{A^2+A\sqrt[3]{B}+\sqrt[3]{B^2}}$

ង. $\sqrt{A}-\sqrt{B}=\frac{A-B}{\sqrt{A}+\sqrt{B}}$

ច. $\sqrt[3]{A}-\sqrt[3]{B}=\frac{A^3-B^3}{\sqrt[3]{A^2}+\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2}}$

ឆ. $\sqrt[3]{A}+\sqrt[3]{B}=\frac{A^3+B^3}{\sqrt[3]{A^2}-\sqrt[3]{A}\sqrt[3]{B}+\sqrt[3]{B^2}}$

លំហាត់គំរូ ១៩

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to+\infty}\left(\sqrt{x^2+5x-1}-\sqrt{x^2+3x+2}\right)$

ខ. $\lim\limits_{x\to\infty}\left(\frac{x^3}{2x^2-1}-\frac{x^2}{2x+1}\right)$

គ. $\lim\limits_{x\to\infty}\left(x-\sqrt{x^2+1}\right)$ ឃ. $\lim\limits_{x\to3}\left(\frac{1}{x-3}-\frac{6}{x^2-9}\right)$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to+\infty}\left(\sqrt{x^2+5x-1}-\sqrt{x^2+3x+2}\right)$, រាងមិនកំណត់$+\infty-\infty$

តាង $A=\lim\limits_{x\to+\infty}\left(\sqrt{x^2+5x-1}-\sqrt{x^2+3x+2}\right)$

យើងប្រើរូបមន្ត $(a-b)(a+b)=a^2-b^2$

នាំឱ្យ យើងបាន៖ $\lim\limits_{x\to+\infty}\left(\sqrt{x^2+5x-1}-\sqrt{x^2+3x+2}\right)$ អាចសរសេរទៅជា

$A=\lim\limits_{x\to+\infty}\frac{\sqrt{\left(x^2+5x-1\right)^2}-\sqrt{\left(x^2+3x+2\right)^2}}{\sqrt{x^2+5x-1}+\sqrt{x^2+3x+2}}$

$A=\lim\limits_{x\to+\infty}\frac{\left(x^2+5x-1\right)-\left(x^2+3x+2\right)}{\sqrt{x^2+5x-1}+\sqrt{x^2+3x+2}}$

$A=\lim\limits_{x\to+\infty}\frac{x^2+5x-1-x^2-3x-2}{\sqrt{x^2+5x-1}+\sqrt{x^2+3x+2}}$

$A=\lim\limits_{x\to+\infty}\frac{2x-3}{\sqrt{x^2\left(1+\frac{5}{x}-\frac{1}{x^2}\right)}+\sqrt{x^2\left(1+\frac{3}{x}+\frac{2}{x^2}\right)}}$; $\left(|x|=x \text{ នៅពេល } x\to+\infty\right)$

$A=\lim\limits_{x\to+\infty}\frac{2x-3}{x\sqrt{1+\frac{5}{x}-\frac{1}{x^2}}+x\sqrt{1+\frac{3}{x}+\frac{2}{x^2}}}$

$A=\lim\limits_{x\to+\infty}\frac{x\left(2-\frac{3}{x}\right)}{x\left(\sqrt{1+\frac{5}{x}-\frac{1}{x^2}}+\sqrt{1+\frac{3}{x}+\frac{2}{x^2}}\right)}$

$A=\lim\limits_{x\to+\infty}\frac{2-\frac{3}{x}}{\sqrt{1+\frac{5}{x}-\frac{1}{x^2}}+\sqrt{1+\frac{3}{x}+\frac{2}{x^2}}}$

$A=\frac{2-\frac{3}{\infty}}{\sqrt{1+\frac{5}{\infty}-\frac{1}{\infty^2}}+\sqrt{1+\frac{3}{\infty}+\frac{2}{\infty^2}}}$

$A=\frac{2-0}{\sqrt{1+0-0}+\sqrt{1+0+0}}$

$A=\frac{2-0}{1+1}$

$A=1$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}\left(\sqrt{x^2+5x-1}-\sqrt{x^2+3x+2}\right)=1}$

ខ. $\lim\limits_{x\to\infty}\left(\frac{x^3}{2x^2-1}-\frac{x^2}{2x+1}\right)$, រាងមិនកំណត់$+\infty-\infty$

យើងបាន $\lim\limits_{x\to\infty}\left(\frac{x^3}{2x^2-1}-\frac{x^2}{2x+1}\right)=\lim\limits_{x\to\infty}\frac{x^3(2x+1)-x^2(2x^2-1)}{(2x^2-1)(2x+1)}$

$=\lim\limits_{x\to\infty}\frac{2x^4+x^3-2x^4+x^2}{(2x^2-1)(2x+1)}$

$=\lim\limits_{x\to\infty}\frac{x^3(1+\frac{1}{x})}{x^2(2-\frac{1}{x^2})x(2+\frac{1}{x})}$

$=\lim\limits_{x\to\infty}\frac{\cancel{x^3}(1+\frac{1}{x})}{\cancel{x^3}(2-\frac{1}{x^2})(2+\frac{1}{x})}$

$=\lim\limits_{x\to\infty}\frac{1+\frac{1}{x}}{(2-\frac{1}{x^2})(2+\frac{1}{x})}$

$=\frac{1+\frac{1}{\infty}}{(2-\frac{1}{\infty^2})(2+\frac{1}{\infty})}$

$=\frac{1}{4}$

ដូចនេះ $\boxed{\lim\limits_{x\to\infty}\left(\frac{x^3}{2x^2-1}-\frac{x^2}{2x+1}\right)=\frac{1}{4}}$

គ. $\lim\limits_{x\to\infty}\left(x-\sqrt{x^2+1}\right)$, រាងមិនកំណត់$+\infty-\infty$

៦.១ ការគណនាដោយប្រើរូបមន្តគ្រឹះ ករណី $x \to x_0$

⚠ សម្គាល់

បើរាងមិនកំណត់ $x \to x_0$ ណាមួយ នោះគេត្រូវតាង $k = x - x_0$ ឬ $k = x_0 - x$ កាលណា $x \to x_0$នោះយើងបាន $k \to 0$ បន្ទាប់មក យើងគណនាដោយប្រើរូបមន្តគ្រឹះខាងលើ ។

លំហាត់គំរូ ២០

គណនាលីមីតខាងក្រោម៖

$\lim\limits_{x\to\frac{\pi}{3}} \frac{1-2\cos x}{\sin 3x}$ $\lim\limits_{x\to 2} \frac{2-x}{\sin\frac{2\pi}{x}}$ $\lim\limits_{x\to\pi} \frac{\cos\frac{\pi x}{x+\pi}}{\pi - x}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\frac{\pi}{2}} \frac{\cos x}{\tan 2x}$, រាងមិនកំណត់ $\frac{0}{0}$

តាង $k = x - \frac{\pi}{2} \Rightarrow x = k + \frac{\pi}{2}$

កាលណា $x \to \frac{\pi}{2}$ នោះ $k \to 0$ យើងបាន៖

$$\begin{aligned}
\lim_{x\to\frac{\pi}{2}} \frac{\cos x}{\tan 2x} &= \lim_{k\to 0} \frac{\cos(k+\frac{\pi}{2})}{\tan 2(k+\frac{\pi}{2})} \\
&= \lim_{k\to 0} \frac{\cos(k+\frac{\pi}{2})}{\tan 2(\pi+2k)} \\
&= \lim_{k\to 0} \frac{-\sin k}{\tan 2k} \\
&= -\lim_{k\to 0}\left[\frac{\sin k}{k} \times \frac{2k}{\tan 2k} \times \frac{1}{2}\right] \\
&= -\frac{1}{2}\lim_{k\to 0}\frac{\sin k}{k} \times \lim_{k\to 0}\frac{2k}{\tan 2k} \\
&= -\frac{1}{2} \times 1 \times 1 \\
&= -\frac{1}{2}
\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to\frac{\pi}{2}} \frac{\cos x}{\tan 2x} = -\frac{1}{2}}$

ខ. $\lim\limits_{x\to\frac{\pi}{3}} \frac{1-2\cos x}{\sin 3x}$, រាងមិនកំណត់ $\frac{0}{0}$

តាង $k = x - \frac{\pi}{3} \Rightarrow x = k + \frac{\pi}{3}$

កាលណា $x \to \frac{\pi}{3}$ នោះ $k \to 0$ យើងបាន៖

$$\lim_{x\to\frac{\pi}{3}} \frac{1-2\cos x}{\sin 3x} = \lim_{k\to 0} \frac{1-2\cos(k+\frac{\pi}{3})}{\sin 3(k+\frac{\pi}{3})}$$

យើងមាន

$$\begin{aligned}
\bullet \sin 3(k+\frac{\pi}{3}) &= \sin(\pi+3k) \\
&= -\sin 3k
\end{aligned}$$

$$\begin{aligned}
\bullet \cos(\frac{\pi}{3}+k) &= \cos\frac{\pi}{3}\cos k - \sin\frac{\pi}{3}\sin k \\
&= \frac{1}{2}\cos k - \frac{\sqrt{3}}{2}\sin k \\
&= \frac{1}{2}(\cos k - \sqrt{3}\sin k)
\end{aligned}$$

យើងបាន៖

$$\begin{aligned}
\lim_{k\to 0} \frac{1-2\cos(k+\frac{\pi}{3})}{\sin 3(k+\frac{\pi}{3})} &= \lim_{k\to 0} \frac{1-2\frac{1}{2}(\cos k - \sqrt{3}\sin k)}{-\sin 3k} \\
&= \lim_{k\to 0}\left[\frac{1-\cos k+\sqrt{3}\sin k}{k}\right] \times \frac{k}{-\sin 3k} \\
&= \left[\lim_{k\to 0}\frac{1-\cos k}{k} + \sqrt{3}\lim_{k\to 0}\frac{\sin k}{k}\right] \times \left(-\lim_{k\to 0}\frac{3k}{\sin 3k} \times \frac{1}{3}\right) \\
&= (0+\sqrt{3})(-1\times\frac{1}{3}) \\
&= -\frac{\sqrt{3}}{3}
\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to\frac{\pi}{3}} \frac{1-2\cos x}{\sin 3x} = -\frac{\sqrt{3}}{3}}$

គ. $\lim\limits_{x\to 2} \frac{2-x}{\sin\frac{2\pi}{x}}$, រាងមិនកំណត់ $\frac{0}{0}$

តាង $z = \frac{2}{x} \Rightarrow x = \frac{2}{z}$

បើ $x \to 2$ នោះ $z \to 1$

យើងបាន $\lim\limits_{z\to1}\dfrac{2-x}{\sin\frac{2\pi}{x}}=\lim\limits_{z\to1}\dfrac{2-\frac{2}{z}}{\sin\pi z}$

$$=\lim_{z\to1}\frac{2\left(1-\frac{1}{z}\right)}{\sin\pi z}$$
$$=2\lim_{z\to1}\frac{\frac{z-1}{z}}{\sin\pi z}$$
$$=2\lim_{z\to1}\frac{\frac{z-1}{z}}{\sin\pi z}$$
$$=2\lim_{z\to1}\frac{z-1}{z\sin\pi z}$$

តាង $z=1-u\Rightarrow u=1-z$ បើ$z\to1$ នោះ $u\to0$

យើងបាន $2\lim\limits_{z\to1}\dfrac{z-1}{z\sin\pi z}=2\lim\limits_{u\to0}\dfrac{-u}{(1-u)\sin(\pi-\pi u)}$

$$=-2\lim_{u\to0}\left[\frac{1}{1-u}\times\frac{\pi u}{\sin\pi u}\times\frac{1}{\pi}\right]$$
$$=-2\frac{1}{\pi}\lim_{u\to0}\frac{1}{1-u}\lim_{u\to0}\frac{\pi u}{\sin\pi u}$$
$$=-2\times\frac{1}{\pi}\times\frac{1}{1-0}\times1$$
$$=-\frac{2}{\pi}$$

ដូចនេះ $\boxed{\lim\limits_{x\to2}\frac{2-x}{\sin\frac{2\pi}{x}}=-\frac{2}{\pi}}$

ឃ. $\lim\limits_{x\to\pi}\frac{\cos\frac{\pi x}{x+\pi}}{\pi-x}$, រាងមិនកំណត់ $\frac{0}{0}$

តាង $t=\frac{\pi x}{x+\pi}\Rightarrow x=\frac{\pi t}{\pi-t}$ បើ $x\to\pi$ នោះ $t\to\frac{\pi}{2}$ យើងបាន

$\lim\limits_{x\to\pi}\dfrac{\cos\frac{\pi x}{x+\pi}}{\pi-x}=\lim\limits_{t\to\frac{\pi}{2}}\dfrac{\cos t}{\pi-\frac{\pi t}{\pi-t}}$

តាង $u=\frac{\pi}{2}-t\Rightarrow t=\frac{\pi}{2}-u$ បើ $t\to\frac{\pi}{2}$ នោះ $u\to0$ យើងបាន៖

$$\lim_{t\to\frac{\pi}{2}}\frac{\cos t}{\pi-\frac{\pi t}{\pi-t}}=\lim_{u\to0}\frac{\cos\left(\frac{\pi}{2}-u\right)}{\pi-\frac{\pi\left(\frac{\pi}{2}-u\right)}{\pi-\left(\frac{\pi}{2}-u\right)}}=\lim_{u\to0}\frac{\sin u}{\pi-\frac{\frac{\pi^2}{2}-\pi u}{\frac{\pi}{2}+u}}$$
$$=\lim_{u\to0}\frac{\sin u}{\frac{\frac{\pi^2}{2}+\pi u-\frac{\pi^2}{2}+\pi u}{\frac{\pi}{2}+u}}=\lim_{u\to0}\frac{\sin u}{\frac{2\pi u}{\frac{\pi}{2}+u}}$$
$$=\lim_{u\to0}\left[\frac{\sin u}{u}\times\frac{\frac{\pi}{2}+u}{2\pi}\right]$$
$$=\lim_{u\to0}\frac{\sin u}{u}\times\lim_{u\to0}\frac{\frac{\pi}{2}+u}{2\pi}$$
$$=1\times\frac{1}{4}$$
$$=\frac{1}{4}$$

ដូចនេះ $\boxed{\lim\limits_{x\to\pi}\frac{\cos\frac{\pi x}{x+\pi}}{\pi-x}=\frac{1}{4}}$

៦.២ ការគណនាដោយប្រើរូបមន្តគ្រឹះ ករណី $x\to\infty$

សម្គាល់

បើរាងមិនកំណត់ $x\to\infty$ នោះគេត្រូវតាង $k=\frac{1}{x}$ កាលណា $x\to\infty$ នោះយើងបាន $k\to0$ បន្ទាប់មកយើងគណនាដោយប្រើរូបមន្តគ្រឹះខាងលើ ។

លំហាត់គំរូ ២១

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\infty}(3x+1)\sin\frac{2\pi x}{x-1}$

ខ. $\lim\limits_{x\to\infty}(7x+2)\cos\frac{\pi x}{2(x+1)}$

គ. $\lim\limits_{x\to\infty}(2x+1)\sin\frac{\pi x}{(x+3)}$

ឃ. $\lim\limits_{x\to+\infty}\frac{(1+x)\sin x}{3+x^2}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\infty}(3x+1)\sin\frac{2\pi x}{x-1}$, រាងមិនកំណត់ $1\times\infty$

$\lim\limits_{x\to\infty}(3x+1)\sin\frac{2\pi x}{x-1}=\lim\limits_{x\to\infty}[3(x-1)+4]\sin\left[2\pi\left(1+\frac{1}{1-x}\right)\right]$

តាង $t=\frac{1}{x-1}\Rightarrow x-1=\frac{1}{t}$, បើ $x\to\infty$ នោះ $t\to0$, យើងបាន៖

$$\lim_{x\to\infty}[3(x-1)+4]\times\sin\left[2\pi\left(1+\frac{1}{1-x}\right)\right]=\lim_{t\to 0}\left(\frac{3}{t}+4\right)\times\sin(2\pi+2\pi t)$$
$$=\lim_{t\to 0}\left(\frac{3}{t}+4\right)\times\sin 2\pi t$$
$$=\lim_{t\to 0}\left[\frac{3\sin 2\pi t}{t}+4\sin 2\pi t\right]$$
$$=\lim_{t\to 0}\left[\frac{\sin 2\pi t}{2\pi t}\times 6\pi+4\sin 2\pi t\right]$$
$$=6\pi\lim_{t\to 0}\frac{\sin 2\pi t}{2\pi t}+4\lim_{t\to 0}\sin 2\pi t$$
$$=6\pi\times 1+4\times 0$$
$$=6\pi$$

ដូចនេះ $\boxed{\lim_{x\to\infty}(3x+1)\sin\frac{2\pi x}{x-1}=6\pi}$

ខ. $\lim_{x\to\infty}(7x+2)\cos\frac{\pi x}{2(x+1)}$, រាងមិនកំណត់ $1\times\infty$

$\lim_{x\to\infty}(7x+2)\cos\frac{\pi x}{2(x+1)}=\lim_{x\to\infty}[7(x+1)-5]\times\cos\left[\frac{\pi}{2}(1-\frac{1}{x+1})\right]$

តាង $k=\frac{1}{x+1}\Rightarrow x+1=\frac{1}{k}$, បើ $x\to\infty$ នោះ $k\to 0$ យើងបាន៖

$$\lim_{x\to\infty}[7(x+1)-5]\times\cos\left[\frac{\pi}{2}(1-\frac{1}{x+1})\right]=\lim_{k\to 0}\left(\frac{7}{k}-5\right)\times\cos\left(\frac{\pi}{2}-\frac{\pi k}{2}\right)$$
$$=\lim_{k\to 0}\left(\frac{7}{k}-5\right)\times\sin\frac{\pi k}{2}$$
$$=\lim_{k\to 0}\left(\frac{7\sin\frac{\pi k}{2}}{k}-5\sin\frac{\pi k}{2}\right)$$
$$=\frac{7\pi}{2}\lim_{k\to 0}\sin\frac{\pi k}{2}-5\lim_{k\to 0}\sin\frac{\pi k}{2}$$
$$=\frac{7\pi}{2}\times 1-5\times 0=\frac{7\pi}{2}$$

ដូចនេះ $\boxed{\lim_{x\to\infty}(7x+2)\cos\frac{\pi x}{2(x-1)}=\frac{7\pi}{2}}$

គ. $\lim_{x\to\infty}(2x+1)\sin\frac{\pi x}{(x+3)}$, រាងមិនកំណត់ $1\times\infty$

$\lim_{x\to\infty}(2x+1)\sin\frac{\pi x}{(x+3)}=\lim_{x\to\infty}[2(x+3)-5]\times\sin\left[\pi\left(1-\frac{3}{x+3}\right)\right]$

តាង $u=\frac{1}{x+3}\Rightarrow x+3=\frac{1}{u}$, បើ $x\to\infty$ នោះ $k\to 0$ យើងបាន៖

$$\lim_{x\to\infty}[2(x+3)-5].\sin\left[\pi\left(1-\frac{3}{x+3}\right)\right]=\lim_{u\to 0}\left(\frac{2}{u}-5\right)\times\sin(\pi-3\pi u)$$
$$=\lim_{u\to 0}\left(\frac{2}{u}-5\right)\times\sin 3\pi u$$
$$=\lim_{u\to 0}\left(\frac{2\sin 3\pi u}{u}-5\sin 3\pi u\right)$$
$$=\lim_{u\to 0}\frac{\sin 3\pi u}{3\pi u}\times 6\pi-\lim_{u\to 0}5\sin 3\pi u$$
$$=1\times 6\pi-5\times 0$$
$$=6\pi$$

ដូចនេះ $\boxed{\lim_{x\to+\infty}(2x+1)\sin\frac{\pi x}{(x+3)}=6\pi}$

ឃ. $\lim_{x\to+\infty}\frac{(1+x)\sin x}{3+x^2}$, រាងមិនកំណត់ $\frac{\infty}{\infty}$

ដោយ $\sin$ មានតម្លៃនៅចន្លោះ -1 និង 1

នាំឱ្យ $\lim_{x\to+\infty}\frac{(1+x)\sin x}{3+x^2}=\lim_{x\to+\infty}\frac{(1+x)}{3+x^2}$ $\quad -1\le\sin x\le 1$

$$=\lim_{x\to+\infty}\frac{x(\frac{1}{x}+1)}{x(\frac{3}{x}+x)}$$
$$=\lim_{x\to+\infty}\frac{\frac{1}{x}+1}{\frac{3}{x}+x}$$
$$=\frac{\frac{1}{+\infty}+1}{\frac{3}{+\infty}+(+\infty)}$$
$$=0$$

ដូចនេះ

$\lim_{x\to\infty}\frac{(1+x)\sin x}{3+x^2}=0$

៧ របៀបគណនាលីមីតនៃអនុគមន៍ អ៊ិចស្ប៉ូណង់ស្យែល

⚠ សម្គាល់

ដើម្បីគណនាលីមីតនៃអនុគមន៍អ៊ិចស្ប៉ូណង់ស្យែលយើងត្រូវ ចងចាំរូបមន្តមួយចំនួនដូចខាងក្រោម៖

; $\lim_{x\to+\infty}\frac{x^n}{e^x}=0$, $n\ge 0$ $\lim_{x\to 0}\frac{a^x-1}{x}=\ln a$, $(a>0)$ $\lim_{x\to 0}\frac{(1+x)^k-1}{x}=k$ $\lim_{x\to 0}(1+x)^{\frac{1}{x}}=e$ $\lim_{x\to\infty}(1+\frac{1}{x})^x=e$ $\lim_{x\to\infty}(1+\frac{a}{x})^x=e^a$

$\lim_{x\to+\infty}a^x=\begin{cases}+\infty & \text{បើ } a>1\\ 0 & \text{បើ } 0<a<1\end{cases}$ $\quad\lim_{x\to-\infty}a^x=\begin{cases}+\infty & \text{បើ } 0<a<1\\ 0 & \text{បើ } a>1\end{cases}$

លំហាត់គំរូ ២២

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to 0}\frac{e^{2x}-1}{x}$ ខ. $\lim_{x\to+\infty}\frac{2e^x+e^{2x}+1}{e^x+1}$ គ. $\lim_{x\to+\infty}\frac{e^x-x^2+x+2}{x^2}$

ឃ. $\lim\limits_{x\to+\infty}\frac{e^x-x}{2e^x+1}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to0}\frac{e^{2x}-1}{x}$, រាងមិនកំណត់ $\frac{0}{0}$

យើងមាន $\lim\limits_{x\to0}\dfrac{e^{2x}-1}{x}=\left[\lim\limits_{x\to0}\dfrac{e^{2x}-1}{2x}\times2\right]$
$=2\lim\limits_{x\to0}\dfrac{e^{2x}-1}{2x}$
$=2$

ដូចនេះ៖ $\boxed{\lim\limits_{x\to0}\frac{e^x-1}{x}=2}$

ខ. $\lim\limits_{x\to+\infty}\frac{2e^x+e^{2x}+1}{e^x+1}$

• របៀបទី១

$\lim\limits_{x\to+\infty}\frac{2e^x+e^{2x}+1}{e^x+1}$, រាងមិនកំណត់ $\frac{\infty}{\infty}$

យើងមាន $\lim\limits_{x\to+\infty}\dfrac{2e^x+e^{2x}+1}{e^x+1}=\lim\limits_{x\to+\infty}\dfrac{e^{2x}+2e^x+1}{e^x+1}$
$=\lim\limits_{x\to+\infty}\dfrac{(e^x+1)^2}{e^x+1}$
$=\lim\limits_{x\to+\infty}e^x+1$
$=+\infty+1$
$=+\infty$

• របៀបទី២

$\lim\limits_{x\to+\infty}\frac{2e^x+e^{2x}+1}{e^x+1}$, រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន៖ $\lim\limits_{x\to+\infty}\dfrac{2e^x+e^{2x}+1}{e^x+1}=\lim\limits_{x\to+\infty}\dfrac{e^x(2+e^x+\frac{1}{e^x})}{e^x(1+\frac{1}{e^x})}$
$=\lim\limits_{x\to+\infty}\dfrac{2+e^x+\frac{1}{e^x}}{1+\frac{1}{e^x}}$
$=\dfrac{2+\infty+0}{1+0}$
$=+\infty$

ដូចនេះ៖ $\boxed{\lim\limits_{x\to+\infty}\frac{2e^x+e^{2x}+1}{e^x+1}=+\infty}$

គ. $\lim\limits_{x\to+\infty}\frac{e^x-x^2+x+2}{x^2}$, រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន៖ $\lim\limits_{x\to+\infty}\dfrac{e^x-x^2+x+2}{x^2}=\lim\limits_{x\to+\infty}\dfrac{x^2(\frac{e^x}{x^2}-1+\frac{1}{x^2}+\frac{2}{x^2})}{x^2}$
$=\lim\limits_{x\to+\infty}\left(\dfrac{e^x}{x^2}-1+\dfrac{1}{x^2}+\dfrac{2}{x^2}\right)=+\infty$

ដូចនេះ៖ $\boxed{\lim\limits_{x\to+\infty}\frac{e^x-x^2+x+2}{x^2}=+\infty}$

ឃ. $\lim\limits_{x\to+\infty}\frac{e^x-x}{2e^x+1}$, រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន៖ $\lim\limits_{x\to+\infty}\dfrac{e^x-x}{2e^x+1}=\lim\limits_{x\to+\infty}\dfrac{e^x(1-\frac{x}{e^x})}{e^x(2+\frac{1}{e^x})}$
$=\lim\limits_{x\to+\infty}\dfrac{1-\frac{x}{e^x}}{2+\frac{1}{e^x}}$
$=\dfrac{1}{2}$

ដូចនេះ៖ $\boxed{\lim\limits_{x\to+\infty}\frac{e^x-x}{2e^x+1}=\frac{1}{2}}$

៨ របៀបគណនាលីមីតនៃអនុគមន៍ លោការីត

⚠ សម្គាល់

ដើម្បីគណនាលីមីតនៃអនុគមន៍លោការីត យើងត្រូវចងចាំរូបមន្តមួយចំនួនដូចខាងក្រោម៖

ក. $\lim\limits_{x\to0}\frac{\ln(1+x)}{x}=1$

ខ. $\lim\limits_{x\to0^+}\ln x=-\infty$

គ. $\lim\limits_{x\to+\infty}\ln x=+\infty$

ឃ. $\lim\limits_{x\to+\infty}\frac{\ln x}{x}=0$

ង. $\lim\limits_{x\to1}\frac{\ln x}{x-1}=1$

ច. $\lim\limits_{x\to0^+}x\ln x=0$

ឆ. $\lim\limits_{x\to0^+}x^n\ln x=0; n>0$

ជ. $\lim\limits_{x\to+\infty}\frac{\ln x}{x^n}=0$, $n>0$

ឈ. $\lim\limits_{x\to+\infty}n\ln x=+\infty$, $n>0$

ញ. $\lim\limits_{x\to0}\frac{\log_a(x+1)}{x}=\log_a e$

ដ. $\lim\limits_{x\to0^+}\log_a x=\begin{cases}-\infty, a>0\\+\infty, 0<a<1\end{cases}$

ឋ. $\lim\limits_{x\to+\infty}\log_a x=\begin{cases}+\infty, a>1\\-\infty, 0<a<1\end{cases}$

ដូចនេះ $\boxed{\lim\limits_{x\to 0}\frac{\ln(x^2-x+1)}{x}=-1}$

៩ របៀបគណនាលីមីតរាងមិនកំណត់ $1^\infty ,\infty^0 ,\infty^\infty$

⚠ សម្គាល់

ដើម្បីគណនាលីមីតរាងមិនកំណត់ $1^\infty,\infty^0 ,\infty^\infty ,0^\infty ,0^0$ យើងត្រូវចាំរូបមន្តសំខាន់ៗមួយចំនួនគឺ៖

ក. $\lim\limits_{x\to 0}(1+x)^{\frac{1}{x}}=e$ ខ. $\lim\limits_{x\to\infty}(1+\frac{1}{x})^x=e$ គ. $\lim\limits_{x\to\infty}(1+\frac{a}{x})^x=e^a$

ឃ. $\lim\limits_{x\to 0}\frac{\ln(1+x)}{x}=1$ ង. $\lim\limits_{x\to 0}\frac{e^x-1}{x}=1$ ច. $\lim\limits_{x\to 0}\frac{a^x-1}{x}=\ln a$

លំហាត់គំរូ ២៤

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\infty}\left(\frac{x}{x+1}\right)^x$ ខ. $\lim\limits_{x\to 0}(1+\sin x)^{\frac{1}{x}}$ គ. $\lim\limits_{x\to\infty}\left(\frac{2x+3}{2x+1}\right)^{x+1}$

ឃ. $\lim\limits_{x\to 0}(\cos x)^{\frac{1}{x}}$ ង. $\lim\limits_{x\to+\infty}x^{\frac{1}{\ln x}}$ ច. $\lim\limits_{x\to+\infty}x^{\frac{1}{x}}$

ឆ. $\lim\limits_{x\to 0^+}x^x$ ជ. $\lim\limits_{x\to 0^+}x^{\frac{1}{\frac{3\ln x}{2}}}$

ដំណោះស្រាយ

ក. $\lim\limits_{x\to\infty}\left(\frac{x}{x+1}\right)^x$, រាងមិនកំណត់ ∞^∞

យើងបាន
$$\begin{aligned}\lim_{x\to\infty}\left(\frac{x}{x+1}\right)^x &= \lim_{x\to\infty}\left(1-\frac{1}{x+1}\right)^x\\
&=\lim_{x\to\infty}\left(1-\frac{1}{x+1}\right)^{-(x+1)\times\frac{x}{-(x+1)}}\\
&=\lim_{x\to\infty}\left[\left(1-\frac{1}{x+1}\right)^{-(x+1)}\right]^{-\frac{x}{x+1}}\\
&=e^{\lim\limits_{x\to\infty}-\frac{x}{x+1}}\\
&=e^{-\lim\limits_{x\to\infty}\frac{\cancel{x}}{\cancel{x}(1+\frac{1}{x})}}\\
&=e^{-\lim\limits_{x\to\infty}\frac{1}{1+\frac{1}{x}}}\\
&=e^{-\frac{1}{1+\frac{1}{\infty}}}\\
&=e^{-1}\\
&=\frac{1}{e}\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to\infty}\left(\frac{x}{x+1}\right)^x=\frac{1}{e}}$

ខ. $\lim\limits_{x\to 0}(1+\sin x)^{\frac{1}{x}}$,រាងមិនកំណត់ 1^∞

ដោយ $\lim\limits_{x\to 0}(1+\sin x)^{\frac{1}{x}}=\lim\limits_{x\to 0}(1+\sin x)^{\frac{1}{\sin x}\times\frac{\sin x}{x}}$

យើងបាន
$$\begin{aligned}\lim_{x\to 0}(1+\sin x)^{\frac{1}{\sin x}\times\frac{1}{x}}&=\lim_{x\to 0}\left[(1+\sin x)^{\frac{1}{\sin x}}\right]^{\frac{\sin x}{x}}\\
&=e^{\lim\limits_{x\to 0}\frac{\sin x}{x}}\\
&=e\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to 0}(1+\sin x)^{\frac{1}{x}}=e}$

គ. $\lim\limits_{x\to\infty}\left(\frac{2x+3}{2x+1}\right)^{x+1}$,រាងមិនកំណត់ ∞^∞

យើងបាន $\lim\limits_{x\to\infty}\left(\frac{2x+3}{2x+1}\right)^{x+1}=\lim\limits_{x\to\infty}\left(1+\frac{2x+3}{2x+1}-1\right)^{x+1}$

$$=\lim_{x\to\infty}\left(1+\frac{2}{2x+1}\right)^{x+1}$$

$$=\lim_{x\to\infty}\left(1+\frac{1}{\frac{2x+1}{2}}\right)^{x+1}$$

$$=\lim_{x\to\infty}\left(1+\frac{1}{\frac{2x+1}{2}}\right)^{\frac{2x+1}{2}\times\frac{2}{2x+1}\times(x+1)}$$

$$=\lim_{x\to\infty}\left[\left(1+\frac{1}{\frac{2x+1}{2}}\right)^{\frac{2x+1}{2}}\right]^{\frac{2(x+1)}{2x+1}}$$

$$=e^{\lim\limits_{x\to\infty}\frac{\cancel{x}(2+\frac{2}{x})}{\cancel{x}(2+\frac{1}{x})}}$$

$$=e^{\frac{2+\frac{2}{\infty}}{2+\frac{1}{\infty}}}$$

$$=e^{\frac{1+0}{1+0}}$$

$$=e$$

ដូចនេះ $\boxed{\lim\limits_{x\to\infty}\left(\frac{2x+3}{2x+1}\right)^{x+1}=e}$

ឃ. $\lim\limits_{x\to0}(\cos x)^{\frac{1}{x}}$,រាងមិនកំណត់ 1^{∞}

យើងបាន $\lim\limits_{x\to0}(\cos x)^{\frac{1}{x}}=\lim\limits_{x\to0}(1-2\sin^2\frac{x}{2})^{\frac{1}{x}}$

$$=\left[\left(1-2\sin^2\tfrac{x}{2}\right)^{\frac{1}{-2\sin^2\frac{x}{2}}}\right]^{\frac{-2\sin^2\frac{x}{2}}{x}}$$

$$=e^{\lim\limits_{x\to0}\frac{-2\sin^2\frac{x}{2}}{x}}$$

$$=e^{\lim\limits_{x\to0}\left[\frac{\sin\frac{x}{2}}{\frac{x}{2}}\times(-\sin\frac{x}{2})\right]}$$

$$=e^{1\times0}=1$$

ដូចនេះ $\boxed{\lim\limits_{x\to0}(\cos x)^{\frac{1}{x}}=1}$

ង. $\lim\limits_{x\to+\infty}x^{\frac{1}{\ln x}}$, រាងមិនកំណត់ ∞^0

យើងបាន $\lim\limits_{x\to+\infty}x^{\frac{1}{\ln x}}=\lim\limits_{x\to+\infty}\left(e^{\ln x}\right)^{\frac{1}{\ln x}}$

$$=\lim_{x\to+\infty}e^{\frac{\ln x}{\ln x}}$$

$$=e$$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}x^{\frac{1}{\ln x}}=e}$

ច. $\lim\limits_{x\to+\infty}x^{\frac{1}{x}}$, រាងមិនកំណត់ ∞^0

យើងបាន $\lim\limits_{x\to+\infty}x^{\frac{1}{x}}=\lim\limits_{x\to+\infty}\left(e^{\ln x}\right)^{\frac{1}{x}}$

$$=\lim_{x\to+\infty}e^{\frac{\ln x}{x}}$$

$$=e^0$$

$$=1$$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}x^{\frac{1}{x}}=1}$

ឆ. $\lim\limits_{x\to0^+}x^x$, រាងមិនកំណត់ 0^0

• របៀបទី១

យើងបាន $\lim\limits_{x\to0^+}x^x=\lim\limits_{x\to0^+}[1+(x-1)]^x$

$$=\lim_{x\to0^+}\left\{[1+(x-1)]^{\frac{1}{x-1}}\right\}^{x(x-1)}$$

$$=e^{\lim\limits_{x\to0^+}x(x-1)}$$

$$=e^0$$

$$=1$$

• របៀបទី២

យើងបាន $\lim\limits_{x\to0^+}x^x=\lim\limits_{x\to0^+}\left(e^{\ln x}\right)^x$

$$=\lim_{x\to0^+}e^{\lim\limits_{x\to0^+}x\ln x}$$

$$=e^0$$

$$=1$$

ដូចនេះ $\boxed{\lim\limits_{x\to0^+}x^x=1}$

ជ. $\lim\limits_{x\to0^+}x^{\frac{1}{\frac{3\ln x}{2}}}$

យើងបាន $\lim\limits_{x\to0^+}x^{\frac{1}{\frac{3\ln x}{2}}}=\lim\limits_{x\to0^+}\left(e^{\ln x}\right)^{\frac{1}{\frac{3\ln x}{2}}}$

$$=e^{\lim\limits_{x\to0^+}\frac{\ln x}{\frac{3\ln x}{2}}}$$

$$=e^{\lim\limits_{x\to0^+}\frac{2\ln x}{3\ln x}}$$

$$=e^{\frac{2}{3}}$$

ដូចនេះ $\boxed{\lim\limits_{x\to0^+}x^{\frac{1}{3\ln x}}=e^{\frac{2}{3}}}$

១០ របៀបគណនាលីមីតរាងមិនកំណត់ $0\times\infty$

⚠ សម្គាល់

ដើម្បីគណនាគណនាលីមីតរាងមិនកំណត់ $0\times\infty$ យើងត្រូវបំលែងរាងយ៉ាងណាឲ្យចូលរាង $\frac{0}{0},\frac{\infty}{\infty}$។

លំហាត់គំរូ ២៥

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to+\infty}(x^3+x)e^{-x}$ ខ. $\lim\limits_{x\to+\infty}(x^3e^{-x}+xe^{-1})$ គ. $\lim\limits_{x\to0}x\left(\frac{1+\cos x}{\sin x}\right)$

ឃ. $\lim\limits_{x\to0}\frac{1}{x}\left(\frac{e^x+3x^2}{x^3}\right)$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to+\infty}(x^3+x)e^{-x}$, រាងមិនកំណត់ $0\times\infty$

យើងបាន $$\begin{aligned}\lim_{x\to+\infty}(x^3+x)e^{-x} &= \lim_{x\to+\infty}\left[(x^3+x)\times\frac{1}{e^x}\right]\\ &= \lim_{x\to+\infty}\left[\frac{x^3\left(1+\frac{1}{x^2}\right)}{e^x}\right]\\ &= \lim_{x\to+\infty}\frac{x^3}{e^x}\\ &= 0\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}(x^3+x)e^{-x}=0}$

ខ. $\lim\limits_{x\to+\infty}(x^3e^{-x}+xe^{-1})$, រាងមិនកំណត់ $0\times\infty$

យើងបាន $$\begin{aligned}\lim_{x\to+\infty}(x^3e^{-x}+xe^{-1}) &= \lim_{x\to+\infty}\left(\frac{x^3}{e^x}+\frac{x}{e^x}\right)\\ &= \lim_{x\to+\infty}\frac{x^3}{e^x}+\lim_{x\to+\infty}\frac{x}{e^x}\\ &= 0+0=0\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to+\infty}(x^3e^{-x}+xe^{-1})=0}$

គ. $\lim\limits_{x\to0}x\left(\frac{1+\cos x}{\sin x}\right)$, រាងមិនកំណត់ $0\times\infty$

យើងបាន $$\begin{aligned}\lim_{x\to0}x\left(\frac{1+\cos x}{\sin x}\right) &= \lim_{x\to0}\left(\frac{x+x\cos x}{\sin x}\right)\\ &= \lim_{x\to0}\left[\frac{x}{\sin x}+\frac{x\cos x}{\sin x}\right]\\ &= \lim_{x\to0}\frac{x}{\sin x}+\lim_{x\to0}\frac{x\cos x}{\sin x}\\ &= \lim_{x\to0}\frac{x}{\sin x}+\lim_{x\to0}x\cot x\\ &= 1+0\\ &= 1\end{aligned}$$

ដូចនេះ $\boxed{\lim\limits_{x\to0}x\left(\frac{1+\cos x}{\sin x}\right)=1}$

ឃ. $\lim\limits_{x\to0^+}\frac{1}{x}\left(\frac{e^x+3x^2}{x^3}\right)$, រាងមិនកំណត់ $0\times\infty$

យើងបាន $\lim\limits_{x\to+\infty}\frac{1}{x}\left(\frac{e^x+3x^2}{x^3}\right)=\lim\limits_{x\to+\infty}\left(\frac{e^x+3x^2}{x^4}\right)$

$$
\begin{aligned}
&=\lim_{x\to+\infty}\left(\frac{e^x}{x^4}+\frac{3x^2}{x^4}\right)\\
&=\lim_{x\to+\infty}\frac{e^x}{x^4}+\lim_{x\to+\infty}\frac{3x^2}{x^4}\\
&=\lim_{x\to+\infty}\frac{e^x}{x^4}+\lim_{x\to+\infty}\frac{3}{x^2}\\
&=+\infty+0\\
&=+\infty
\end{aligned}
$$

ដូចនេះ $\boxed{\lim\limits_{x\to0^+}\frac{1}{x}\left(\frac{e^x+3x^2}{x^3}\right)=+\infty}$

១១ របៀបគណនាលីមីតខិតជិតអនន្តចំពោះស្វ៊ីតចំនួនពិត

សម្គាល់

រូបមន្តផលបូកស្វ៊ីតសំខាន់មួយចំនួនសម្រាប់ដោះស្រាយលំហាត់

១. $1+2+3+\ldots+n=\frac{n(n+1)}{2}$

២. $2+4+6+\ldots+2n=n(n+1)$

៣. $1+3+5+\ldots+(2n-1)=n^2$

៤. $k+(k+1)+(k+2)+\ldots+(k+n-1)=\frac{n(2k+n-1)}{2}$

៥. $1^2+2^2+3^2+\ldots+n^2=\frac{n(n+1)(2n+1)}{6}$

៦. $1^2+3^2+5^2+\ldots+(2n-1)^2=\frac{n(4n^2-1)}{3}$

៧. $1^3+2^3+3^3+\ldots+n^3=\left[\frac{n(n+1)}{2}\right]^2=\frac{n^2(n+1)^2}{4}$

៨. $1^3+3^3+5^3+\ldots+(2n-1)^3=n^2(2n^2-1)$

៩. $1+\frac{1}{2}+\frac{1}{4}+\frac{1}{8}+\ldots+\frac{1}{2^n}+\ldots=2$

១០. $\frac{1}{1\times2}+\frac{1}{2\times3}+\frac{1}{3\times4}+\ldots+\frac{1}{n\times(n+1)}+\ldots=1$

១១. $1+\frac{1}{1!}+\frac{1}{2!}+\frac{1}{3!}+\ldots+\frac{1}{(n-1)!}+\ldots=e$

១២. ផលបូកស្វ៊ីតនព្វន្ត

- $S_n=a_1+a_2+a_3+\ldots+a_n=\frac{n(a_1+a_n)}{2}$

១៣. ផលបូកស្វ៊ីតធរណីមាត្រ

- $S_n=a_1+a_2+a_3+\ldots+a_n=a_1\times\frac{1-q^n}{1-q}$

លំហាត់គំរូ ២៦

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{n\to\infty}\frac{1+2+3+\ldots+n}{n^2}$ ខ. $\lim\limits_{n\to\infty}\frac{1^2+2^2+3^2+\ldots+n^2}{n^3}$

គ. $\lim\limits_{n\to\infty}\left(\frac{1^3+2^3+3^3+\ldots+n^3}{n^3}-\frac{n}{4}\right)$

ឃ. $\lim\limits_{n\to\infty}\left[\frac{1}{1\times2}+\frac{1}{2\times3}+\frac{1}{3\times4}+\ldots+\frac{1}{n\times(n+1)}\right]$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{n\to\infty}\frac{1+2+3+\ldots+n}{n^2}$, រាងមិនកំណត់ $\frac{\infty}{\infty}$

យើងមាន $\lim\limits_{n\to\infty}\dfrac{1+2+3+\ldots+n}{n^2}=\lim\limits_{n\to\infty}\dfrac{n(n+1)}{2n^2}$

$$=\lim_{n\to\infty}\frac{n^2+n}{2n^2}$$

$$=\lim_{n\to\infty}\frac{\cancel{n^2}(1+\frac{1}{n})}{2\cancel{n^2}}$$

$$=\lim_{n\to\infty}\frac{(1+\frac{1}{n})}{2}$$

$$=\frac{(1+\frac{1}{\infty})}{2}$$

$$=\frac{1}{2}$$

ដូចនេះ $\boxed{\lim\limits_{n\to\infty}\frac{1+2+3+\ldots+n}{n^2}=\frac{1}{2}}$

ខ. $\lim\limits_{n\to\infty}\frac{1^2+2^2+3^2+\ldots+n^2}{n^3}$, រាងមិនកំណត់ $\frac{\infty}{\infty}$

យើងបាន $\lim\limits_{n\to\infty}\dfrac{1^2+2^2+3^2+\ldots+n^2}{n^3}=\lim\limits_{n\to\infty}\dfrac{n(n+1)(2n+1)}{6n^3}$

$$=\lim_{n\to\infty}\frac{\cancel{n^3}(1+\frac{1}{n})(2+\frac{1}{n})}{6\cancel{n^3}}$$

$$=\lim_{n\to\infty}\frac{(1+\frac{1}{n})(2+\frac{1}{n})}{6}$$

$$=\frac{(1+\frac{1}{\infty})(2+\frac{1}{\infty})}{6}$$

$$=\frac{(1+0)(2+0)}{6}$$

$$=\frac{1}{3}$$

ដូចនេះ $\boxed{\lim\limits_{n\to\infty}\frac{1^2+2^2+3^2+\ldots+n^2}{n^3}=\frac{1}{3}}$

គ. $\lim\limits_{n\to\infty}\left(\frac{1^3+2^3+3^3+\ldots+n^3}{n^3}-\frac{n}{4}\right)$, រាងមិនកំណត់ $\infty-\infty$

យើងបាន $\lim\limits_{n\to\infty}\left(\dfrac{1^3+2^3+3^3+\ldots+n^3}{n^3}-\dfrac{n}{4}\right)=\lim\limits_{n\to\infty}\left[\dfrac{n^2(n+1)^2}{4n^3}-\dfrac{n}{4}\right]$

$$=\lim_{n\to\infty}\left[\frac{(n+1)^2}{4n}-\frac{n}{4}\right]$$

$$=\lim_{n\to\infty}\left(\frac{n^2+2n+1}{4n}-\frac{n}{4}\right)$$

$$=\lim_{n\to\infty}\frac{n^2+2n+1-n^2}{4n}$$

$$=\lim_{n\to\infty}\frac{2n+1}{4n}$$

$$=\lim_{n\to\infty}\frac{\cancel{n}(2+\frac{1}{n})}{4\cancel{n}}$$

$$=\lim_{n\to\infty}\frac{2+\frac{1}{n}}{4}$$

$$=\frac{2+\frac{1}{\infty}}{4}$$

$$=\frac{1}{2}$$

ដូចនេះ $\boxed{\lim\limits_{n\to\infty}\left(\frac{1^3+2^3+3^3+\ldots+n^3}{n^3}-\frac{n}{4}\right)=\frac{1}{2}}$

ឃ. $\lim\limits_{n\to\infty}\left[\frac{1}{1\times2}+\frac{1}{2\times3}+\frac{1}{3\times4}+\ldots+\frac{1}{n\times(n+1)}\right]$, រាងមិនកំណត់ $\frac{\infty}{\infty}$

យើង មាន $\lim\limits_{n\to\infty}\left[\frac{1}{1\times2}+\frac{1}{2\times3}+\frac{1}{3\times4}+\ldots+\frac{1}{n\times(n+1)}\right]$ អាច សរសេរទៅជា

$$=\lim_{n\to\infty}\left[\left(1-\tfrac{1}{2}\right)+\left(\tfrac{1}{2}-\tfrac{1}{3}\right)+\left(\tfrac{1}{3}-\tfrac{1}{4}+\ldots+\tfrac{1}{n}\right)+\tfrac{1}{n+1}\right]$$

$$=\lim_{n\to\infty}\left(1-\tfrac{1}{n+1}\right)$$

$$=1-\tfrac{1}{\infty}$$

$$=1$$

ដូចនេះ $\boxed{\lim\limits_{n\to\infty}\left[\frac{1}{1\times2}+\frac{1}{2\times3}+\frac{1}{3\times4}+\ldots+\frac{1}{n\times(n+1)}\right]=1}$

១២ របៀបគណនាលីមីតរាងមិនកំណត់ ដោយប្រើទ្រឹស្តីបទឡូពីតាល់

រូបមន្តដេរីវេមួយចំនួនដែលចាំបាច់សម្រាប់ដោះស្រាយលំហាត់

អនុគមន៍	ដេរីវេ
$y=a$	$y'=0$
$y=x^n$	$y'=nx^{n-1}$
$y=\frac{1}{x}$	$y'=-\frac{1}{x^2}$
$y=\sqrt{x}$	$y'=\frac{1}{2\sqrt{x}}$
$y=e^x$	$y'=e^x$
$y=a^x$	$y'=a^x\ln a$
$y=\ln x$	$y'=\frac{1}{x}$
$y=\sin x$	$y'=\cos x$
$y=\cos x$	$y'=-\sin x$
$y=\tan x$	$y'=\frac{1}{\cos^2 x}=1+\tan^2 x$
$y=\cot x$	$y'=-\frac{1}{\sin^2 x}=1+\cot^2 x$
$y=u^n$	$y'=nu'u^{n-1}$
$y=\sqrt{u}$	$y'=\frac{u'}{2\sqrt{u}}$
$y=u.v$	$y'=u'v+v'u$
$y=\frac{u}{v}$	$y'=\frac{u'v-v'u}{v^2}$
$y=\ln u$	$y'=\frac{u'}{u}$
$y=\sin u$	$y'=u'\cos u$
$y=\cos u$	$y'=-u'\sin u$
$y=\tan u$	$y'=u'(1+tan^2 u)$
$y=\cot u$	$y'=-u'(1+\cot^2 u)$
$y=e^u$	$y'=u'e^u$

⚠ សម្គាល់

• ជាទូទៅ៖ ដើម្បីគណនាលីមីតដោយប្រើទ្រឹស្តីបទឡូពីតាល់ អាចគណនាបានគឺ ទម្រង់$\frac{0}{0}$ និង $\frac{\infty}{\infty}$ ។ ប៉ុន្តែបើក្រៅពីរាងទាំងពីរ យើងត្រូវបំលែងយ៉ាងណាឲ្យចូលទម្រង់ $\frac{0}{0}$ និង $\frac{\infty}{\infty}$ ។

• ដើម្បីគណនាលីមីតដោយប្រើទ្រឹស្តីបទឡូពីតាល់យើងត្រូវធ្វើដេរីវេ ភាគយក និង ភាគបែង រហូតក្លាយជារាងកំណត់ថ្មីមួយរួច គណនាលីមីតថ្មីនោះ។

$\frac{f(x)}{g(x)}=\frac{f(x')}{g(x')}=\frac{f(x")}{g(x")}=\ldots=\frac{f(x^n)}{g(x^n)}=A,\forall\in\mathbb{R}$

លំហាត់គំរូ ២៧

គណនាលីមីខាងក្រោមដោយប្រើទ្រឹស្តីបទឡូពីតាល់

ក. $\lim_{x\to\infty}\frac{x^2-1}{2x^2+x+2}$ ខ. $\lim_{x\to 2}\frac{\sqrt{x+7}-3}{x-2}$ គ. $\lim_{x\to 1}\frac{1+\cos\pi x}{(x-1)^2}$

ឃ. $\lim_{x\to 0}\frac{e^{ax}-1}{x}$

ដំណោះស្រាយ

គណនាលីមីខាងក្រោមដោយប្រើទ្រឹស្តីបទឡូពីតាល់

ដូចនេះ: $\boxed{\lim_{x\to 0}\frac{e^{ax}-1}{x}=a}$



លំហាត់គំរូទី១

ដោយប្រើនិយមន័យចូរបង្ហាញថា

ក. $\lim\limits_{x\to -2}\frac{x^2-1}{x+1}=-3$ ខ. $\lim\limits_{x\to a}(mx+b)=ma+b$ គ. $\lim\limits_{x\to 0}\sqrt[3]{x}=0$

ឃ. $\lim\limits_{x\to 2}\sqrt{x}=\sqrt{2}$ ង. $\lim\limits_{x\to 2^-}\sqrt{(x-2)(x-3)}=0$ ច. $\lim\limits_{x\to 2}\frac{x^2-1}{x}=\frac{3}{2}$

ដំណោះស្រាយ

ដោយប្រើនិយមន័យចូរបង្ហាញថា

ក. $\lim\limits_{x\to -2}\frac{x^2-1}{x+1}=-3$

តាមនិយមន័យ: $\forall\,\varepsilon>0\,,\,|f(x)-L|<\varepsilon$

យើងមាន$|f(x)-L|<\varepsilon=\left|\dfrac{x^2-1}{x+1}-(-3)\right|<\varepsilon$

$$\Leftrightarrow\left|\frac{(x+2)(x+1)}{x+1}\right|<\varepsilon$$

$$\Leftrightarrow|x+2|<\varepsilon=\alpha$$

ដោយ$\forall\,\varepsilon>0\,,\exists\,\alpha=\varepsilon>0$ ដែល $|x+2|<\varepsilon$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ: $\boxed{\lim\limits_{x\to -2}\frac{x^2-1}{x+1}=-3}$

ខ. $\lim\limits_{x\to a}(mx+b)=ma+b$

តាមនិយមន័យ: $\forall\,\varepsilon>0\,,\,|f(x)-L|<\varepsilon$

យើងមាន$|f(x)-L|<\varepsilon\Leftrightarrow|(mx+b)-(ma+b)|<\varepsilon$

$$\Leftrightarrow|mx+b-ma-b|<\varepsilon$$

$$\Leftrightarrow|m(x-a)|<\varepsilon$$

$$\Leftrightarrow|m||x-a|<\varepsilon$$

$$\Leftrightarrow|x-a|<\frac{\varepsilon}{|m|}$$

ដោយ$\forall\ \varepsilon>0\ ,\ \exists\ \alpha=\frac{\varepsilon}{|m|}>0$ ដែល $|x-a|<\varepsilon$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ: $\boxed{\lim\limits_{x\to a}(mx+b)=ma+b}$

គ. $\lim\limits_{x\to 0}\sqrt[3]{x}=0$

តាមនិយមន័យ: $\forall\,\varepsilon>0\,,\,|f(x)-L|<\varepsilon$

យើងមាន$|f(x)-L|<\varepsilon\Leftrightarrow|\sqrt[3]{x}-0|<\varepsilon$

$$\Leftrightarrow|\sqrt[3]{x}|<\varepsilon$$

$$\Leftrightarrow(|\sqrt[3]{x}|)^3<\varepsilon^3$$

$$\Leftrightarrow|x|<\varepsilon^3$$

ដោយ$\forall\,\varepsilon>0\,,\exists\,\alpha=\varepsilon^3>0$ ដែល $|x-0|<\varepsilon$ ឬ $|x|<\varepsilon$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ: $\boxed{\lim\limits_{x\to 0}\sqrt[3]{x}=0}$

ឃ. $\lim\limits_{x\to 2}\sqrt{x}=\sqrt{2}$

តាមនិយមន័យ: $\forall\,\varepsilon>0\,,\,|f(x)-L|<\varepsilon$

យើងមាន$|f(x)-L|<\varepsilon\Leftrightarrow|\sqrt{x}-\sqrt{2}|<\varepsilon$

$$\Leftrightarrow|(\sqrt{x}-\sqrt{2})(\sqrt{x}+\sqrt{2})|<\varepsilon(\sqrt{x}+\sqrt{2})$$

$$\Leftrightarrow|x-2|<\varepsilon(\sqrt{x}+\sqrt{2})$$

ដោយ$\forall\,\varepsilon>0\,,\exists\,\alpha=\varepsilon\left(\sqrt{x}+\sqrt{2}\right)>0$ ដែល $|x-2|<\varepsilon$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ: $\boxed{\lim\limits_{x\to 2}\sqrt{x}=\sqrt{2}}$

ង. $\lim\limits_{x\to 2^-}\sqrt{(x-2)(x-3)}=0$

តាមនិយមន័យ: $\forall\ \varepsilon>0\ ,\ |f(x)-L|<\varepsilon$

យើងមាន$|f(x)-L|<\varepsilon\Leftrightarrow|\sqrt{(x-2)(x-3)}-0|<\varepsilon$

$$\Leftrightarrow|\sqrt{(x-2)(x-3)}|<\varepsilon$$
$$\Leftrightarrow(|\sqrt{(x-2)(x-3)}|)^2<\varepsilon^2$$
$$\Leftrightarrow|(x-2)(x-3)|<\varepsilon^2$$
$$\Leftrightarrow|x-2||x-3|<\varepsilon^2$$
$$\Leftrightarrow|x-2|<\frac{\varepsilon^2}{|x-3|}(*)$$

ដោយ $x\to 2^-$ យើងបាន៖

$$1<x<2\Leftrightarrow 1-3<x-3<2-3$$
$$\Leftrightarrow -2<x-3<-1$$
$$\Leftrightarrow\frac{-2}{-1}<\frac{x-3}{-1}<\frac{-1}{-1}$$
$$\Leftrightarrow 1<-(x-3)<2$$
$$\Leftrightarrow|-(x-3)|<2$$
$$\Leftrightarrow|x-3|<2(**)$$

តាម $(*)$ និង $(**)$ យើងបាន $|x-2^-|<\frac{\varepsilon^2}{2}$

ដោយ$\forall\ \varepsilon>0\ ,\ \exists\ \alpha=\frac{\varepsilon^2}{2}>0$ ដែល $|x-2|<\varepsilon$

នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ: $\boxed{\lim\limits_{x\to 2^-}\sqrt{(x-2)(x-3)}=0}$

ច. $\lim\limits_{x\to 2}\frac{x^2-1}{x}=\frac{3}{2}$

តាមនិយមន័យ: $\forall\ \varepsilon>0\ ,\ |f(x)-L|<\varepsilon$

យើងមាន$|f(x)-L|<\varepsilon\Leftrightarrow\left|\frac{x^2-1}{x}-\frac{3}{2}\right|<\varepsilon$

$$\Leftrightarrow\left|\frac{2(x^2-1)-3x}{2x}\right|<\varepsilon$$
$$\Leftrightarrow\left|\frac{2x^2-3x-2}{2x}\right|<\varepsilon$$
$$\Leftrightarrow\left|\frac{(x-2)(2x+1)}{2x}\right|<\varepsilon$$
$$\Leftrightarrow\frac{|x-2||2x+1|}{|2x|}<\varepsilon$$
$$\Leftrightarrow\frac{|x-2||2x+1|}{|2x|}\times\frac{|2x|}{|2x+1|}<\varepsilon\frac{|2x|}{|2x+1|}$$
$$\Leftrightarrow|x-2|<\varepsilon\frac{|2x|}{|2x+1|}$$

ដោយ $x\to 2$ យើងបាន៖

ចំពោះ $|2x|$

$$1<x<3\Leftrightarrow 2<2x<6$$
$$\Leftrightarrow|2x|<6(*)$$

ហើយម្យ៉ាងទៀតចំពោះ $|2x+1|$

$$1<x<3\Leftrightarrow 2<2x<6$$
$$\Leftrightarrow 2+1<2x+1<6+1$$
$$\Leftrightarrow 3<2x+1<7$$
$$\Leftrightarrow|2x+1|<7(**)$$

តាម$(*)$ និង $(**)$យើងបាន$|x-2|<\frac{6}{7}\varepsilon$

ដោយ$\forall\ \varepsilon>0\ ,\ \exists\ \alpha=|x-2|<\frac{6}{7}\varepsilon$ ដែល $|x-2|<\frac{6}{7}\varepsilon$ នាំឱ្យ $|f(x)-L|<\varepsilon$

ដូចនេះ: $\boxed{\lim\limits_{x\to 2}\frac{x^2-1}{x}=\frac{3}{2}}$

លំហាត់គំរូទី២

ដោយប្រើនិយមន័យចូរបង្ហាញថា

ក. $\lim\limits_{x\to 2^-}\frac{3x-1}{x-2}=-\infty$ ខ. $\lim\limits_{x\to 2^+}\frac{4x+1}{x-2}=+\infty$ គ. $\lim\limits_{x\to-\infty}\frac{x^2-2}{x^2+2}=1$

ឃ. $\lim\limits_{x\to+\infty}\frac{3x+1}{x}=3$ ង. $\lim\limits_{x\to-\infty}(x^2-x-1)=+\infty$ ច. $\lim\limits_{x\to+\infty}\frac{x^2+3}{2-x}=-\infty$

ដំណោះស្រាយ

ដោយប្រើនិយមន័យចូរបង្ហាញថា

ក. $\lim\limits_{x\to 2^-}\frac{3x-1}{x-2}=-\infty$

តាមនិយមន័យ $\forall M>0\ ,\ f(x)<-M$

យើងមាន$f(x)<-M\Leftrightarrow\frac{3x-1}{x-2}<-M$

$$\Leftrightarrow 3+\frac{5}{x-2}<-M$$
$$\Leftrightarrow\frac{5}{x-2}<-M-3$$
$$\Leftrightarrow\frac{5}{x-2}<-(M+3)$$
$$\Leftrightarrow\left|\frac{5}{x-2}\right|<|-(M+3)|$$
$$\Leftrightarrow\frac{5}{|x-2|}<M+3$$
$$\Leftrightarrow|x-2|>\frac{5}{M+3}$$

យក $\alpha = \frac{5}{M+3} > 0$
យើងបាន $\forall M > 0$, $\exists \alpha = \frac{5}{M+3}$ ដែល $|x-2| < \alpha$
នាំឱ្យ $f(x) < -M$

ដូចនេះ $\boxed{\lim\limits_{2^-} \frac{3x-1}{x-2} = -\infty}$

ខ. $\lim\limits_{x\to 2^+} \frac{4x+1}{x-2} = +\infty$
តាមនិយមន័យ $\forall M > 0$, $f(x) > M$
យើងមាន $f(x) > M \Leftrightarrow \dfrac{4x+1}{x-2} > M$
$$\Leftrightarrow 4 + \frac{9}{x-2} > M$$
ដើម្បីឲ្យ $4 + \frac{9}{x-2} > M$ យើងគ្រាន់តែយក $\frac{9}{x-2} > M$
យើងបាន $\frac{9}{x-2} > M \Leftrightarrow |x-2| < \frac{9}{M}$ យក $\alpha = \frac{9}{M} > 0$
យើងបាន $\forall M > 0$, $\exists \alpha = \frac{9}{M}$ ដែល $|x-2| < \alpha$ នាំឱ្យ $f(x) > M$

ដូចនេះ $\boxed{\lim\limits_{2^+} \frac{4x+1}{x-2} = +\infty}$

គ. $\lim\limits_{x\to -\infty} \frac{x^2-2}{x^2+2} = 1$
តាមនិយមន័យ $\forall \varepsilon > 0$, $|f(x) - L| < \varepsilon$
យើងមាន $|f(x)-L| < \varepsilon \Leftrightarrow \left|\dfrac{x^2-2}{x^2+2} - 1\right| < \varepsilon$
$$\Leftrightarrow \left|\frac{-4}{x^2+2}\right| < \varepsilon$$
$$\Leftrightarrow \frac{4}{x^2+2} < \varepsilon$$
$$\Leftrightarrow x^2 + 2 > \frac{4}{\varepsilon}$$
$$\Leftrightarrow x^2 < \frac{4}{\varepsilon}$$
$$\Leftrightarrow |x| < \sqrt{\frac{4}{\varepsilon}}$$
ដោយ $x \to -\infty$ នោះ $|x| = -x$
យើងបាន $-x < \sqrt{\frac{4}{\varepsilon}} \Leftrightarrow x > -\frac{2}{\sqrt{\varepsilon}}$ យក $N = \frac{2}{\sqrt{\varepsilon}} > 0$
យើងបាន $\forall \varepsilon > 0 < \exists N = \frac{2}{\varepsilon}$ ដែល $x < -N$ នាំឱ្យ $|f(x) - L| < \varepsilon$

ដូចនេះ $\boxed{\lim\limits_{x\to -\infty} \frac{x^2-2}{x^2+2} = 1}$

ឃ. $\lim\limits_{x\to +\infty} \frac{3x+1}{x} = 3$
